ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរកសិកម្មខេត្តកណ្ដាល

# សៀវភៅបច្ចេកទេសដាំដំណាំបន្លែ




















ឆ្នាំ២០១៣

# សៀវភៅបច្ចេកទេសដាំដំណាំបន្លែ

រៀបចំដោយមន្ទីរកសិកម្មខេត្តកណ្ដាល

អ្នករៀបរៀង
លោក អ៊ិន ចាន់យ៉ារិទ្ធ
អ្នកផ្ដល់យោបល់ និង កែសម្រួល
លោក ប៊ុនធួន ស៊ីមូណា
លោក លឹម ងួនគ្រុយ
លោក ហ៊ី សុផល
លោក ឡុង រ៉ា
លោក ផា ចាម
លោក ប៉ាន់ ខេមរិន្ទ
លោក ហាស់ វុទ្ធី
លោក អាង វណ្ណា

ម.ព.ឯ.ក AIDOC
Code: 247-050
Date:
Donated by:

# មាតិកា

**សេចក្តីផ្តើម**

I-**អត្ថន័យនៃបន្លែ** ........ ០២

II-**សារៈសំខាន់នៃដំណាំបន្លែ** ........ ០៣

១-សារៈសំខាន់ផ្នែកម្ហូបអាហារ ........ ០៣

២-សារៈសំខាន់ផ្នែកសេដ្ឋកិច្ច ........ ០៥

**ដំណាំត្រាវ** ........ ០៦

I.**លក្ខខណ្ឌបរិស្ថាន** ........ ០៦

១.លក្ខខណ្ឌដី ........ ០៦

២.ពន្លឺ ........ ០៧

II.**បច្ចេកទេសដាំដុះ** ........ ០៧

១-ប្រភេទដី ........ ០៧

២-ប្រភេទដីដែលត្រូវប្រើ ........ ០៩

៣-ការដាំដុះ ........ ១០

៤-ចន្លោះជួរ ........ ១២

III.**ការថែទាំ** ........ ១៣

IV.**ការប្រមូលផល** ........ ១៥

**ដំណាំស្ពៃក្តោប** ........ ១៨

**១.លក្ខណៈទូទៅ** ........ ១៨

**២.អំពីបរិស្ថាន** ........ ១៨

ខ-ក្រុមជម្ងឺបាក់តេរី:........................................២៥

គ-ក្រុមវីរុស:........................................២៦

**៧.ការប្រមូលផល**........................................២៦

**ដំណាំត្រសក់ចំណារ**........................................២៧

**១.ស្ថានភាពទូទៅ**........................................២៧

ក.វីតាមីន និង សារធាតុរ៉ែ:........................................២៧

ខ.សីតុណ្ហភាព:........................................២៧

**២.បច្ចេកទេសដាំដុះ**........................................២៨

២.១-ពូជ:........................................២៨

២.២-ការជ្រើសរើស និង រៀបចំដី:........................................២៨

២.៣-វិធីសាស្ត្រដាំដុះមានពីររបៀប:........................................២៩

**៣-របៀបស្រោចស្រព**........................................៣២

**៤-ដកស្មៅ និងភ្ជុំជ្រួយដី**........................................៣៣

**៥-ការដោតចំណារ**........................................៣៣

**៦-ការប្រើប្រាស់ជី**........................................៣៤

**៧-ជម្ងឺ និង សត្វល្អិត**........................................៣៥

ក-អំពីជម្ងឺផ្សិត........................................៣៥

ខ-ជម្ងឺបង្កឡើងដោយវីរុស:........................................៣៨

គ-ជំងឺបង្កឡើងដោយបាក់តេរី:........................................៤១

**៨-សត្វល្អិតសំខាន់ៗលើដំណាំត្រសក់**........................................៤២

**៩-ការប្រមូលផល**........................................៤៤

**ដំណាំសាលាដ់ហ្សេង** ........................................ ៤៥

**១.ស្ថានភាពទូទៅ** ........................................ ៤៥

**២.លក្ខណៈជីវសាស្ត្រ** ........................................ ៤៥

**៣.បច្ចេកទេសដាំដុះ** ........................................ ៤៧

**៤.ការប្រមូលផល** ........................................ ៥១

**ដំណាំខាត់ណាដើម** ........................................ ៥៣

**១.ស្ថានភាពទូទៅ** ........................................ ៥៣

**២.បច្ចេកទេសដាំដុះ** ........................................ ៥៤

ក.រដូវកាលដាំដុះ ........................................ ៥៤

ខ.ការជ្រើសរើសពូជ ........................................ ៥៤

គ.ការជ្រើសរើសនិងរៀបចំដី ........................................ ៥៤

ឃ-ការដាំដុះ ........................................ ៥៦

ង-ការស្រោចស្រពៈ ........................................ ៥៧

ច-ការជ្រុំជ្រួយដីៈ ........................................ ៥៧

ឆ-ការដាក់ជីៈ ........................................ ៥៧

**៣-សត្វល្អិត និង ជម្ងឺ** ........................................ ៥៨

ក-ជម្ងឺសំខាន់ៗៈ ........................................ ៥៨

ខ-សត្វល្អិតសំខាន់ៗៈ ........................................ ៥៩

**៤-ការប្រមូលផល** ........................................ ៦១

**ដំណាំត្រប់**........................................................................................៦២

**១-ស្ថានភាពទូទៅ**............................................................................... ៦២

**២-លក្ខខ័ណ្ឌអាកាសធាតុ និង ដី**......................................................៦៣

២.១-លក្ខខណ្ឌអាកាសធាតុ........................................................៦៣

២.២-លក្ខខណ្ឌដី.......................................................................... ៦៤

**៣-បច្ចេកទេសដាំដុះ**............................................................................. ៦៤

៣.១-រដូវកាលដាំដុះ....................................................................៦៤

៣២.-ការជ្រើសរើសពូជ............................................................... ៦៥

៣.៣-ការរៀបចំដី..........................................................................៦៥

៣៤.-ការដាំដុះ............................................................................. ៦៦

៣៥.-ការស្រោចស្រព.................................................................... ៦៨

៣៦.-ការកំចាត់ស្មៅ...................................................................... ៦៨

៣៧.-ការដាក់ជី.......................................................................... ៦៩

**៤-ជម្ងឺ និង សត្វល្អិត**.......................................................................... ៦៩

៤.១-ជម្ងឺសំខាន់ៗ........................................................................... ៦៩

៤២.-សត្វល្អិត..............................................................................៧១

**៥-ការប្រមូលផល**................................................................................. ៧២

**ដំណាំប៉េងប៉ោះ**.......................................................................................៧៤

**១-លក្ខណទូទៅ**.........................................................................................៧៤

**២-បច្ចេកទេសដាំដុះ**..........................................................៧៥

២.១-ការជ្រើសរើសរដូវ..............................................៧៥

២.២-ការជ្រើសរើសពូជ..............................................៧៦

២.៣-ការរៀបចំដី..................................................... ៧៦

២.៤-ការបណ្ដុះកូន..................................................... ៧៧

២.៥-ការដាំដុះ.......................................................... ៧៨

**៣-ការថែទាំ**...................................................................... ៧៨

៣.១-ការជ្រួយដី.......................................................... ៧៨

៣.២-ការស្រោចស្រព.................................................. ៧៨

៣.៣-ការដោតចំណារ..................................................៧៩

៣.៤-ការដាក់ជី.......................................................... ៨១

**៤-អំពីជម្ងឺ និងសត្វល្អិត**..................................................៨២

៤.១-អំពីជម្ងឺសំខាន់ៗ..................................................៨២

៤.២-អំពីសត្វល្អិតស៊ីដំណាំ..........................................៨៥

**៥-ការប្រមូលផល**...............................................................៨៦

ឯកសារយោង.......................................................... ៨៨

# សេចក្ដីផ្ដើម

នៅលើពិភពលោកយើងនេះ កំណើនមនុស្សមានឆាប់រហ័ស ធ្វើឲ្យអ្នកប្រាជ្ញវិទ្យាសាស្ត្រ ឬ អ្នកបច្ចេកទេសខិតខំយ៉ាងខ្លាំង ដើម្បីដោះស្រាយបញ្ហាដែលបានកើតមានឡើងឲ្យស្របនឹងកំណើននេះ ។

អ្នកប្រាជ្ញផ្នែកបច្ចេកទេសកសិកម្ម បានខិតខំរកគ្រប់មធ្យោបាយក្នុងទិសដៅបង្កើនផលិតផលម្ហូបអាហារ ដើម្បីផ្គត់ផ្គង់សេចក្ដីត្រូវការហូបចុក និង ត្រូវជំនះឧបសគ្គជាច្រើនដើម្បីទទួលបានជោគជ័យលើការងារខាងលើនេះ អ្នកបច្ចេកទេសមួយចំនួនបានប៉ាន់ស្មានថាមានកុមារប្រហែល១៥០០០០០០នាក់ បានត្រូវស្លាប់ក្នុង១ឆ្នាំៗ ដោយសារការខ្វះខាតម្ហូបអាហារ និងជម្ងឺដែលបណ្ដាលមកពីការខ្វះរូបធាតុចិញ្ចឹមជាពិសេសនៅក្នុងប្រទេសដែលក្រីក្រ ។

ម្ហូបអាហារទាក់ទងនឹងដំណាំជាច្រើនប្រភេទដូចជាៈ ស្រូវ ពោតជាពិសេសបន្លែ និងផ្លែឈើគ្រប់ប្រភេទ។ល។ បន្លែស្ថិតនៅក្នុងចំណោមម្ហូបអាហារយ៉ាងសំខាន់ ដែលគេធ្វើការដាំដុះនៅលើផ្ទៃដីមួយចំនួនធំនៅគ្រប់ប្រទេស ហើយជួនកាលស្ថិតនៅក្នុងក្របខណ្ឌវិទ្យាសាស្ត្របច្ចេកទេសយ៉ាងខ្ពស់ទៀតផង។ បច្ចេកទេសដ៏ទំនើបៗត្រូវបានយកប្រើក្នុងន័យបង្កើនទិន្នផល និងបង្កើនគុណភាពផលិតផល ក្នុងគោលបំណងបំពេញឲ្យសេចក្ដីត្រូវការរបស់មនុស្ស ពិសេសនៅតំបន់ទីក្រុងធំៗ

ដែលសំបូរទៅដោយមនុស្សរស់នៅ។ កាលពីដើមការដាំដំណាំបន្លែច្រើនធ្វើឡើងសំរាប់ផ្គត់ផ្គង់សេចក្តីត្រូវការក្នុងគ្រួសារ ឬលក់ដូរបន្តិចបន្តួចតែប៉ុណ្ណោះ ប៉ុន្តែពេលបច្ចុប្បន្ននេះសភាពការណ៍សេដ្ឋកិច្ចមានការប្រែប្រួលប្រជាជនមានចំនួនកាន់តែច្រើនឡើងៗ សេចក្តីត្រូវការដំណាំបន្លែសម្រាប់ផ្សំជាអាហារក៏មានកំរិតកាន់តែខ្ពស់ ការដាំបន្លែក៏ត្រូវមានការវិវត្តន៍ប្លែកខុសពីមុន គឺមានការដាំដុះលើផ្ទៃដីធំធេងសម្រាប់លក់ដូរនៅតាមទីផ្សារធំៗរបៀបជាបន្លែស្រស់ និង ប្រើប្រាស់ក្នុងរោងចក្រឧស្សាហកម្មទៀតផង ការដាំដុះដំណាំបន្លែនៅក្នុងធាតុអាកាសធម្មតា ឬប្រើប្រាស់បច្ចេកទេសទំនើប ត្រូវយោងទៅលើពេលវេលា តំបន់ដាំដុះ តម្លៃ មធ្យោបាយដឹកជញ្ជូន ឬតម្រូវការ។ ល។ និង ។ ល។

## I <u>អត្ថន័យនៃបន្លែ</u>

*•អ្វីទៅដែលហៅថាបន្លែ ?*

បន្លែគឺជាផ្នែករុក្ខជាតិ ដែលគេបរិភោគរួមផ្សំជាមួយអាហារមូលដ្ឋាន។ ការប្រើប្រាស់ផលិតផលដំណាំឲ្យទៅជាបន្លែ ឬ ជាអាហារមូលដ្ឋាន ក៏ប្រែប្រួលទៅតាមតំបន់ ឬ ប្រទេសនិមួយៗដែរ។

ឧទាហរណ៍: ប្រទេសកម្ពុជា ថៃ វៀតណាម ឡាវ ប្រើស្រូវជាអាហារមូលដ្ឋាន។ ប្រទេសភាគច្រើននៅអឺរ៉ុបប្រើស្រូវសាឡី ឯប្រទេសខ្លះទៀតនៅអាមេរិកខាងត្បូងគេប្រើពោត និង សណ្តែក ធ្វើជាអាហារ

មូលដ្ឋាន ។

## II សារៈសំខាន់នៃដំណាំបន្លែ

បន្លែជាដំណាំ ដែលមានទំនាក់ទំនងទៅនឹងការរស់នៅរបស់មនុស្សយើងទាំងផ្នែកម្ហូបអាហារ ក៏ដូចជាផ្នែកសេដ្ឋកិច្ច បន្លែមានពីរប្រភេទគឺ :

*ក-បន្លែដែលដុះដោយធម្មជាតិ :* បន្លែប្រភេទនេះភាគច្រើនមានតម្លៃថោក ហើយសំបូរទៅដោយសារធាតុចិញ្ចឹមច្រើនប្រភេទ។

ឧទាហរណ៍: ស្លឹកបាស ស្លឹកងប់ ត្រកួនបឹង ..........

*ខ-បន្លែដែលកសិករយើងធ្វើការដាំដុះ:* បន្លែទាំងនេះត្រូវថែទាំយ៉ាងប្រុងប្រយ័ត្នបំផុត។

ឧទាហរណ៍: ស្ពៃ ខាត់ណា សណ្ដែក ត្រប់ ល្ពៅ ..........

### ១-សារៈសំខាន់ផ្នែកម្ហូបអាហារ

បន្លែជាដំណាំ ដែលមានលក្ខណៈចាំបាច់សម្រាប់សុខភាពរបស់មនុស្ស ព្រមទាំងអាចចាត់ចូលជាអាហារលេខ១ បើគិតពីសារធាតុចិញ្ចឹម។ បន្លែសំបូរទៅដោយសារធាតុចិញ្ចឹមមានប្រូតេអ៊ីន ក្លុយស៊ីតជាតិប្រេង សារធាតុខនិជ ព្រមទាំងជីវជាតិA, B, C, Fe...ជាដើម។ ល។ រូបធាតុចិញ្ចឹមទាំងនោះ អាចទ្រទ្រង់រាងកាយមនុស្សយើងឲ្យរស់រានមានជីវិតមានកំលាំងពលំបរិបូណ៌ ព្រមទាំងប្រាជ្ញាស្មារតីសំរាប់អនុវត្ត

ការងារផ្សេងៗបាន។ យើងមិនអាចរក្សាសុខភាពបានល្អដោយគ្រាន់តែបរិភោគបាយ នំប៉័ង ឬ សាច់ដោយគ្មានបន្លែបានឡើយ។ បន្លែមានច្រើនប្រភេទ ឯការប្រើប្រាស់ជួនកាលមានលក្ខណៈដូចគ្នា ជួនកាលក៏ផ្លាស់ប្ដូរទៅតាមរបៀបផ្សេងៗគ្នាដែរ។ ការបរិភោគបន្លែមិនបានគ្រប់គ្រាន់ អាចបណ្ដាលឲ្យមានជម្ងឺខ្វះជីវជាតិ ដែលជាមូលហេតុធ្វើឲ្យជម្ងឺដ៏ទៃទៀតងាយរាតត្បាតដល់រាងកាយរបស់មនុស្សយើង។

**ឧទាហរណ៍**

-**ជីវជាតិ** A : អាចធ្វើឲ្យភ្នែកភ្លឺល្អ មើលឃើញច្បាស់។ ការខ្វះជីវជាតិ A បណ្ដាលឲ្យភ្នែកឧស្សាហ៍កើតជម្ងឺ មានជម្ងឺខ្វាក់មាន់ជាដើម *ចំពោះកុមារការខ្វះជីវជាតិ A បើស្ថិតក្នុងលក្ខណៈធ្ងន់ធ្ងរ អាចធ្វើអោយគេងងឹតភ្នែកតែម្ដង* ។ ប្រភពដ៏ល្អបំផុតសំរាប់ជីវជាតិ A គឺពពួកស្លឹកបន្លែពណ៌បៃតង ស្លឹកបាស់ ត្រកួន ល្ពៅ ផ្លែឈើដែលមានពណ៌លឿង ដំឡូងជ្វាពណ៌លឿង ប៊័រ ស៊ុតសត្វ ឬ ថ្លើមសត្វ ។ល។

-**ជីវជាតិ** B : ស្បែក ភ្នែក សរសៃប្រសាទ និងឈាមត្រូវការជីវជាតិB។ ការខ្វះជីវជាតិនេះអាចបណ្ដាលឲ្យមានការខ្វះឈាម ខ្សោយកំលាំង ស្បែកស្ងួតក្រៀម ហើមខ្លួន ព្រមទាំងមិនសូវមានប្រាជ្ញាស្មារតីល្អផង។ ជីវជាតិ B ស្ថិតនៅក្នុងស្លឹកបន្លែ អង្ករ ម្សៅស្រូវសាឡី សាច់សត្វ ថ្លើមសត្វ។ល។

**-ជីវជាតិ C:** ជំនួយក្នុងការការពារជម្ងឺជួយឲ្យការមុត ឬ របួសផ្សេងៗឆាប់ជាសះស្បើយ និងជួយឲ្យអញ្ចាញធ្មេញបានល្អ។ ប្រភពដ៏ល្អសម្រាប់ជីវជាតិ C គឺបន្លែយកស្លឹក ផ្លែត្របែក ផ្លែល្ហុង ក្រូចពោធិសាត់ ក្រូចថ្លុង និងក្រូចឆ្មា។ល។

**-ជីវជាតិ ដែក( Fe ):** ជួយការពារជម្ងឺស្លេកស្លាំងដល់កុមារ ស្ត្រីមានផ្ទៃពោះ ការបរិភោគបន្លែឲ្យបានទៀងទាត់អាចធ្វើឲ្យសុខភាពមានលក្ខណៈល្អប្រសើរទៀតផង។

## ២-សារៈសំខាន់ផ្នែកសេដ្ឋកិច្ច

ក្រៅពីដាំដុះសម្រាប់ផ្គត់ផ្គង់ក្នុងគ្រួសារ បន្លែដែលនៅសេសសល់អាចយកទៅលក់នៅតាមទីផ្សារតូចឬធំ ដែលអាចផ្តល់ប្រាក់កាសតិច ឬច្រើនទៅតាមចំនួនផលិតផល។ យើងសង្កេតឃើញថានៅប្រទេសកម្ពុជាប្រជាជនមួយចំនួនមានមុខរបរជាអ្នកដាំបន្លែតែម្តង ជាពិសេសកសិករដែលស្ថិតនៅជាយក្រុងឬនៅតាមតំបន់មាត់ទន្លេ។ ម្យ៉ាងទៀតការដាំបន្លែតាមគ្រួសារ អាចកាត់បន្ថយប្រាក់កាសសំរាប់ទិញបន្លែពីគេ និងអាចមានបន្លែស្រស់ៗថ្មីៗ សំរាប់បរិភោគទៀតផង ។



# ដំណាំត្រាវ

Taro



ត្រាវជាប្រភេទបន្លែមួយបែប ដែលប្រជាកសិករយើងនិយមបរិភោគ ព្រោះគេអាចច្នៃធ្វើជាម្ហូបអាហារព្រមទាំងបង្អែមបានយ៉ាងច្រើន។ ធាង និង ស្លឹកខ្ចីរបស់វាជាបន្លែម្យ៉ាង ដែលអាចយកច្នៃធ្វើជាសម្លរបានយ៉ាងឆ្ងាញ់ពិសារ។ធាងបណ្ដូល ស្លឹកខ្ចីៗ និង ដៃត្រាវក៏ចាត់ចូលជាពពួកបន្លែបៃតងដែលក្នុងនោះសំបូរទៅដោយវីតាមីនអា សម្រាប់ការការពារជម្ងឺខ្វាក់មាន់ និងភ្នែកឡើងបាយរបស់កុមារ និងមនុស្សធំទៀតផង។

## I.លក្ខខណ្ឌបរិស្ថាន

### ១.លក្ខខណ្ឌដី

ដំណាំត្រាវជាប្រភេទដំណាំ ដែលអាចដាំដុះលូតលាស់បានល្អប្រសើរលើប្រភេទដីឥដ្ឋស្រាល ដែលសំបូរទៅដោយសារធាតុចិញ្ចឹមគ្រប់មុខ ជាពិសេសគឺជាតិកំបោរជ្រាបទឹករហ័សព្រមទាំងសំបូរទៅដោយសារធាតុខនិជ។ ប្រភេទដីល្បាយខ្សាច់ ត្រាវអាចដុះលូតលាស់បាន និង ចាក់ឫសបានជ្រៅ ប៉ុន្តែការផ្គត់ផ្គង់ទឹក និង ជី ត្រូវអនុវត្តតាមវិធីសាស្ត្រណែនាំត្រឹមត្រូវទើបទទួលបានទិន្នផលខ្ពស់។ នៅលើប្រភេទដីខ្មៅហើយស្អិតជាមធ្យមនៅរដូវភ្លៀង ត្រូវមានប្រព័ន្ធប្រឡាយបញ្ចេញ

ទឹក។ ជាទូទៅត្រាវអាចដុះលូតលាស់លើប្រភេទដីស្ទើរគ្រប់ប្រភេទ ក្នុងករណីប្រភេទដីឥដ្ឋធម្មតា ត្រូវមានប្រព័ន្ធប្រឡាយរំដោះទឹកត្រឹមត្រូវព្រមទាំងការជ្រើសរើសពូជឲ្យបានល្អ។





ទិដ្ឋភាពចម្ការត្រាវ

### ២.ពន្លឺ

ដំណាំត្រាវត្រូវការពន្លឺថ្ងៃពីចាប់ពី ៩ ទៅ ១០ ម៉ោង ក្នុង២៤ម៉ោង ជួយជម្រុញឲ្យការលូតលាស់ និងជួយបង្កើនទិន្នផលពី២១ ទៅ ២៤% និងបង្កើនគុណភាពឥទ្ធិពលនៃពន្លឺធ្វើឲ្យមានភាពបៃតងចាស់។

## II.បច្ចេកទេសដាំដុះ

### ១ ប្រភេទដី:

☞ **អំពីដី** ត្រាវជាប្រភេទដំណាំយកមើម ដែលអាចដុះលូតលាស់នៅក្នុងស្រទាប់ដីប៉ែកខាងលើ ម៉្យាងទៀតវាជាប្រភេទដំណាំដែលមានវដ្តជីវិតវែង ដូចនេះគឺតម្រូវការដីដែលមានជីវជាតិគ្រប់គ្រាន់។ លក្ខខណ្ឌដែលសមស្របសម្រាប់ធ្វើការដាំដុះគឺដីធូរ ជ្រាបទឹកបានល្អ ស្រទាប់ដាំដុះជ្រៅ ភាគរយដីខ្សាច់ច្រើនជាងដីកណ្តោង និង ដីឥដ្ឋ ជា

ពិសេសគឺដីល្បាយខ្សាច់ ដីល្បាប់មាត់ស្ទឹង ព្រែក ទន្លេ វាមិនអាចដុះលូតលាស់លើប្រភេទដីឥដ្ឋបានឡើយ ប៉ុន្តែវាក៏អាចដុះលូតលាស់ល្អលើដីក្រហមខ្ពង់រាបផងដែរ។ ជាទូទៅកម្រឹតPH ៦-៧ មានអំណោយផលល្អបំផុតសម្រាប់ការដុះលូតលាស់ និងផ្ដល់ទិន្នផលខ្ពស់។

☞ ត្រាវដុះលូតលាស់ល្អ នៅលើដីស្រាលដែលមានជីវជាតិ ធូរ និងជាដីដែលមានសំណើមខ្ពស់ តែមិនមែនជាដីជាំទឹកទេ។ វាក៏អាចដុះបានដែរ លើដីឥដ្ឋគ្រប់ប្រភេទតែគេត្រូវបញ្ចូលទឹកឲ្យបានគ្រប់គ្រាន់នៅរដូវប្រាំង។

☞ នៅក្នុងប្រទេសកម្ពុជាយើង ដីដែលសមស្របគឺជាដីល្បាយខ្សាច់ពិសេសដីនៅតាមដងទន្លេ ដែលជាដីល្បាប់មានជីវជាតិ។

☞ ប្រសិនបើគេដាំត្រាវនៅរដូវប្រាំងលើដីស្ងួត គេត្រូវកប់ទៅក្នុងដីនូវជីកំប៉ុស្ដិ៍ ឬក៏ពពួកសណ្ដែកដើម្បីរក្សាសំណើមរបស់ដី។

☞ ការរៀបចំដី: ត្រូវរាស់ប្រមូលយកស្មៅ ឬកាកសំណល់ផ្សេងៗចេញពីចំការ ហើយភ្ជួរឲ្យជ្រៅបាលដីឲ្យស្ងួត ដើម្បីកាត់បន្ថយការដុះស្មៅ និង កម្ចាត់សមាសភាពចង្រៃពីក្នុង

ដី បន្ទាប់មករាស់បំបែកដីឲ្យម៉ត់ល្អិតកៀរដីឲ្យស្មើ។ ការភ្ជួររាស់ត្រូវធ្វើឲ្យបានពី២ទៅ៣លើក ដើម្បីឲ្យដីមានបន្ទុកខ្យល់គ្រប់គ្រាន់ ព្រមទាំងធ្វើឲ្យដីធូរជ្រាបទឹកបានល្អ ហើយត្រូវលើករងឲ្យមានកំពស់២៥ ទៅ ៣០ សម ទទឹង ១០០ ទៅ ១២០ ស.ម បន្ទាប់មកយកជីគីមីប្រភេទ ១៥ ១៥ ១៥ ចំនួន២០០គក្រ ជីធម្មជាតិ១៥ទៅ១៨តោនសម្រាប់ផ្ទៃដី១ហិកតាបាចលើរង ហើយរាស់លប់កៀរដីឲ្យស្មើនឹងអាចដាំបាន។




## ២-ប្រភេទជីដែលត្រូវប្រើ

ត្រាវជាប្រភេទដំណាំ ដែលត្រូវការជីវជាតិច្រើនប្រភេទ ព្រមទាំងសារធាតុរ៉ែផ្សេងៗ ជាពិសេសសារធាតុអាសូត(N),ផូស្វ័រ (P), ប៉ូតាស្យូម(K), និងកាល់ស្យូម (Ca) ដូចនេះការដាក់ជីត្រូវជ្រើសរើសប្រភេទជីណាដែលមានសារធាតុ N P K និង Ca។ ដើម្បីឲ្យមានធាតុ Ca គេច្រើនប្រើលាមកសត្វ ជាពិសេសលាមក

មាន់ដាក់មុនដាំ១ហិកតាពី៣៦-៤៨រទេះ ក្នុង១ហិកតា ក្រៅពីនោះទៀតគេអាចប្រើជីលាមកជ្រូកពុកផុយឃួរឆ្នាំក៏បានដែរ។

☞ ត្រូវដាក់ជីលាមកសត្វជាការចាំបាច់ដើម្បីឲ្យដីកាន់តែធូរល្អ

☞ ជីប៉ូតាស្យូម(K) វាត្រូវការច្រើនដើម្បីឲ្យមើមធំល្អ។ ជីគីមីដែលគេអាចប្រើគឺជី ១៥. ១៥. ១៥ ចំនួន ២០០គីឡូក្រាមក្នុងមួយហិកតា។

**ការដាក់ជីនេះត្រូវធ្វើជា២ដំណាក់:**

-ដាក់លើកទីមួយៈត្រូវដាក់ក្នុងកម្រិត១ភាគ២ ទៅនឹងការដាក់ទ្រាប់បាត

-ដាក់លើកទីពីរៈ ត្រូវដាក់ក្នុងកម្រិត ១ភាគ២ទៀត គឺនៅពេលត្រាវចាប់ផ្តើមមើម ដាក់តាមចន្លោះជួរ រួចជ្រោយដី។

## ៣-ការដាំដុះ

☞ ត្រូវជ្រើសរើសទីកន្លែងដែលមានពន្លឺថ្ងៃគ្រប់គ្រាន់។ គេត្រូវការកាប់គាស់ដីឲ្យបានជម្រៅពី៣ទៅ៤តឹក និងសម្អាតយកស្មៅចេញ ឬត្រូវភ្ជួរដីយ៉ាងតិចឲ្យបាន២ដង ហើយរាស់ឲ្យបានច្រើនសារ។

☞ គេអាចប្រើចុង ឬ ខ្នែងសម្រាប់ដាំ។ កាលណាចុង ឬ ខ្នែងកាន់តែធំនឹងនាំឲ្យយើងទទួលបានទិន្នផលកាន់តែខ្ពស់ក្នុង

ករណីចុង ឬ ខ្នែងតូចៗគេត្រូវធ្វើការបណ្តុះក្នុងថ្នាលជាមុនសិន ហើយនៅពេលវាដុះបានពី២ ទៅ៣សន្លឹក មានកម្ពស់ ១ ទៅ ២តឹក ទើបអាចយកទៅដាំបាន។

គេត្រូវដាំត្រាវឲ្យបានជ្រៅ គឺជម្រៅ១តឹក ព្រោះមើមវាដុះលូតលាស់ឡើងវិញ។ គេអាចដាំត្រាវបាន២របៀប គឺដាំដោយលើករង (នៅរដូវវស្សា) និង បុករណ្តៅរួចដាំ (រដូវប្រាំង)។ វិធីបុករណ្តៅហើយដាំនេះ គេច្រើនអនុវត្តន៍នៅតាមតំបន់មាត់ទន្លេបាសាក់ ទន្លេមេគង្គ។ ក្រោយធ្វើដីរួចគេត្រូវយកអង្រែ មកបុករណ្តៅក្នុងអង្កត់ផ្ចិត១ទៅ១.៥តឹក និងជម្រៅ ២ទៅ ២.៥តឹក។ ក្រោយពេលដាំរួចគេត្រូវយកស្លឹកចេក ឬ ស្លឹកឈើងាប់មកគ្រប ដើម្បីកុំឲ្យត្រាវស្លោក និងរក្សាសំណើមដីបានយូរ។

☞ គេអាចដាំត្រាវឆ្លាស់ជាមួយស្រូវបាន គឺដាំស្រូវនៅរដូវវស្សា និងដាំត្រាវនៅរដូវប្រាំង ឬដាំចម្រុះជាមួយដំណាំផ្សេងៗទៀតដូចជា ប៉េងបោះ សណ្តែកដី សណ្តែកបាយ ឬ បន្លែផ្សេងៗទៀត។

☞ ការដាំត្រាវនៅរដូវវស្សា ឲ្យផលយូរជាងដាំនៅរដូវប្រាំង ព្រោះត្រាវត្រូវការពន្លឺថ្ងៃច្រើន សម្រាប់ការលូតលាស់នៃ

មើម ក៏ប៉ុន្តែកម្រិតនៃពន្លឺថ្ងៃដែលដំណាំនេះត្រូវការគឺពីតិចទៅមធ្យម។

**ដំណាក់កាលលូតលាស់របស់ដំណាំត្រាវៈ**

**ក) ដំណាក់កាលបង្កបង្កើត.** (រយៈពេល៨សប្តាហ៍) ក្នុងដំណាក់កាលនេះត្រាវចាប់ផ្តើមដុះ ឫស និង ស្លឹក។

**ខ)ដំណាក់កាលលូតលាស់**(រយៈពេល២០សប្តាហ៍) ក្នុងដំណាក់កាលនេះត្រាវកំពុងដុះស្លឹកច្រើន និង លូតកម្ពស់កាន់តែខ្ពស់។ មើមក៏ចាប់រីកបន្តិចម្តងៗ។

**ខ)ដំណាក់កាលពង្រីកមើម** ក្នុងដំណាក់កាលលូតលាស់របស់ស្លឹកថយចុះ តែមើមរបស់ត្រាវកាន់តែរីកយ៉ាងឆាប់រហ័ស។

## ៤-ចន្លោះដាំ

☞ ដាំលើករង(ចំពោះរដូវវស្សា)

-កម្ពស់រង: ២ ទៅ ៣ តឹក

-ទទឹង: ៥ ទៅ ៦តឹក

-បណ្តោយ: តាមលទ្ធភាព

-ចន្លោះគុម្ព: ៤ ទៅ ៥តឹក

-ចន្លោះជួរ: ៦ទៅ៨តឹក គេដាំតែមួយជួរក្នុងមួយរង។

☞ ការបុកដាំ ( ចំពោះរដូវប្រាំង )

-ចន្លោះរណ្តៅ: ៦ x ៦ តឹក ឬ ៧,៥x ៧,៥ តឹក

## III.ការថែទាំ

ដើម្បីឲ្យដីធូរ ព្រមទាំងទប់ស្កាត់ការដុះលូតលាស់នូវស្មៅចង្រៃ និងការលូតលាស់ប្រព័ន្ធឫស ដំបូងត្រូវដករម្លស់កូនត្រាវចេញខ្លះ ព្រមទាំងដកស្មៅចេញ ហើយយកកូនចបមុខតូចជ្រំដីឲ្យផុសក្បែរគុម្ពពេញផ្ទៃរង ហើយផ្អាកការស្រោចទឹករយៈពេល១ថ្ងៃ ធ្វើឲ្យដីស្ងួតខ្យល់ចេញចូលបានល្អ។ រយៈពេលសមស្របក្នុងការជ្រំជ្រួយដី គឺធ្វើឡើងក្រោយពីដាំបានចំនួន ១៥ ទៅ ១៨ថ្ងៃ កាលណាពន្យារពេលជ្រំជ្រួយដី ទុកឲ្យត្រាវពង្រីកមើមកាន់តែធំអាចរំខានដល់ការវិវឌ្ឍន៍ នៃប្រព័ន្ធឫសរបស់វាធ្វើឲ្យមើមតូចហើយខ្លី។ ការផ្តល់ទឹកបានគ្រប់គ្រាន់ និងទៅតាមតម្រូវការរបស់វា ធ្វើឲ្យដំណាំដុះលូតលាស់លឿន ប៉ុន្តែសេចក្តីត្រូវការមិនដូចគ្នាទាំងស្រុងនោះឡើយ គឺអាស្រ័យទៅតាមវគ្គលូតលាស់របស់វាដូចតទៅ:

☞ វគ្គដុះពន្លក: នៅក្នុងវគ្គនេះចាប់តាំងពីដាំរហូតដល់ត្រាវដុះ ១០០% វាត្រូវការសំណើមដីថេរ តែមិនជោគជាំខ្លាំង កាលណាដីស្ងួតបណ្តាលឲ្យក្តាំងដី ធ្វើឲ្យដំណុះមិនស្មើគ្នា ព្រម

ទាំងបាត់ចំនួនដើមច្រើន ដូចនេះគេត្រូវផ្តល់ទឹកព្រឹកល្ងាច តាមវិធីសាស្ត្រជាច្រើន ដែលអាចធ្វើទៅបានដោយប៉ោត ដោយម៉ាស៊ីន។ នៅក្នុងវគ្គនេះកាលណាសំណើមដីសើម ខ្លាំងលើសសេចក្តីត្រូវការ ធ្វើឲ្យកូនដំណាំរលួយឫសទៅវិញ។

- វគ្គលូតលាស់ស្លឹកពិតៈក្រោយពីដុះពន្លក១០០%រយៈពេល ៧ទៅ១០ថ្ងៃ ត្រាវដុះបានស្លឹកពិត ២ ទៅ ៣សន្លឹក វាត្រូវការទឹកកម្រិតមធ្យមប្រហែលគ្នា និងវគ្គដុះពន្លកដែរ ប៉ុន្តែទាបជាងបន្តិចកាលណាស្រោចទឹកខ្លាំងសំណើមដីខ្ពស់ធ្វើឲ្យគល់កូនត្រាវប្រេះ អាចធ្វើឲ្យឃើតយ៉ាវវគ្គកំណាកំណើតមើម។

- វគ្គកំណារកំណើត និងពង្រីកមើមៈ ក្រោយដាំបានរយៈពេល ១៥ ទៅ ១៨ថ្ងៃ គេសង្កេតឃើញត្រាវចាប់ផ្តើមពង្រីកគល់ប៉ោងបន្តិច ពេលនោះវាត្រូវការទឹក និងសារធាតុចិញ្ចឹមកាន់តែច្រើនឡើងៗ រហូតដល់ពេលប្រមូលផល ដូចនេះត្រូវបង្កើនការស្រោចទឹកឲ្យខ្លាំងជាងវគ្គនានា អាចធ្វើឲ្យទិន្នផលត្រាវកាន់តែកើនឡើង ជាទូទៅក្រោយពេលដាំរួចត្រូវស្រោចទឹក ពិសេសនៅរដូវប្រាំងត្រូវជំរះស្មៅឲ្យ

បានស្អាតល្អ ដើម្បីកាត់បន្ថយការបំផ្លាញពីសត្វល្អិត និង ជម្ងឺដើម្បីឲ្យត្រាវចុះមើមបានល្អ គេត្រូវជ្រួយដី និងពូនគល់ ហើយរម្លស់កូនចេញខ្លះ ដើម្បីឲ្យត្រាវមានមើមធំព្រោះ ត្រាវខ្នែងបែកច្រើន។

**ជម្ងឺ និងសត្វល្អិត**

- កាលណាមានការបំផ្លាញដោយពពួកចៃ គេអាចប្រើថ្នាំ កសិកម្ម។
- កាលណាមានការបំផ្លាញដោយជម្ងឺវីរុស (កសិករនិយម ហៅថាក្រាប្រាក់កាក់) និងជម្ងឺរលួយដើម គេត្រូវដក ឬ គាស់ចោលភ្លាមនូវដើមដែលកើតជម្ងឺចេញ សំអាតស្មៅ ក្នុងចំការ និងបរិវេណជុំវិញចំការ ធ្វើការផ្លាស់មុខដំណាំ បំបាត់កាកសំណល់ក្រោយពេលប្រមូលផល។

## IV.ការប្រមូលផល

ការប្រមូលផលត្រូវគិតអំពីវដ្តជីវិតរបស់វា ព្រមទាំងតម្រូវការ ទីផ្សារ កាលណាដកមើមត្រាវមិនទាន់គ្រប់អាយុកាលត្រឹមត្រូវធ្វើឲ្យ បាត់បង់ទិន្នផលព្រមទាំងមិនអាចរក្សាទុកបានយូរផងដែរ ព្រោះវានៅខ្ចី ពេក ប៉ុន្តែបើពន្យាពេលការដកធ្វើឲ្យមើមត្រាវចាស់ស្ពោតក៏អាចបាត់បង់ និងខូចគុណភាពផងដែរ។ ដូចនេះដើម្បីប្រមូលផលទៅតាមបទដ្ឋាន

(ស្តង់ដារ) គឺគេពិនិត្យទៅលើពណ៌នៃស្លឹកវាប្រែពណ៌ពីបៃតងខ្ចីទៅបៃតងចាស់ កំពូលត្រួយរបស់វាលែងលូតលាស់ ដើមប្រែពណ៌ ជាដំណាក់កាលត្រូវប្រមូលផល។

របៀបប្រមូលផលគឺ ដកយកមើមត្រាវដាក់តំរៀបនៅក្នុងចំការក្រោយមកកាត់ស្លឹកចេញ ហើយជញ្ជូនទៅកន្លែងត្រជាក់មិនត្រូវដាក់ហាលថ្ងៃឡើយ។ បើកាលណាគេជញ្ជូនទៅកាន់ទីផ្សារជិតៗ ត្រូវលាងសំអាតមើមជាមុនសិន ប៉ុន្តែក្នុងករណីត្រូវដឹកជញ្ជូនទៅកាន់តំបន់ឆ្ងាយៗ មិនត្រូវលាងទឹកឡើយអាចបណ្តាលឲ្យជាំ រលួយសំបក ទុកមិនបានយូរ។ ប៉ុន្តែដោយឡែកសម្រាប់ការដឹកជញ្ជូន រឺការរក្សាទុកក្នុងប្រព័ន្ធបន្ទប់ត្រជាក់គេត្រូវលាងសំអាតឲ្យស្អាតជាមុន បន្ទាប់មកដាក់ចូលទៅក្នុងកន្ត្រកប្លាស្ទិក តាមលំដាប់ដោយកន្ត្រកនោះមានរន្ធអាចជ្រាបចំហាយត្រជាក់ចូលទៅក្នុងបាន ហើយយកទៅរក្សាទុករយៈពេល ៤០ម៉ោង ទើបបញ្ចុះសីតុណ្ហភាពឲ្យក្រោមសូន្យអង្សាសេ បួនលេខ (-៤ អង្សាសេ) ដើម្បីសំលាប់ពួកមីក្រូសរីរាង្គនិងបាក់តេរីផ្សេងៗ ដែលបណ្តាលឲ្យត្រាវរលួយ។ ជាធម្មតាទិន្នផលជាមធ្យមទៅតាមប្រភេទពូជនិងរដូវកាលដាំដុះ ជាទូទៅគេអាចប្រមូលផលត្រាវក្នុងរវាង៦ ទៅ ១០ ខែក្រោយពេលដាំ តែពូជខ្លះប្រើពេលវែងជាងនេះ។ លក្ខណៈសំគាល់ថាត្រាវអាចប្រមូលផលបាន គឺពេលដែលស្លឹកវាប្រែពណ៌ជាលឿង

ហើយងាប់កសិករខ្លះគាស់យកមើមមកស្ងោរ និង ភ្លក់ទើបសម្រេចចិត្ត គាស់ជាក្រោយ។ មុនពេលគាស់គេត្រូវកាត់ធាង និងស្លឹកចេញដោយ ទុក៤ ទៅ ៥ តឹកពីដី គេអាចទុកដាក់ត្រាវបាន៣ទៅ៤ ខែ ដោយធ្វើឲ្យ វាស្ងួត ការរក្សាទុកត្រាវយូរពេកនឹងនាំឲ្យមើមដុះ។



ផលិតផលកែច្នៃពីត្រាវ

# ដំណាំស្ពៃក្ដោប

Cabbage

## ១.លក្ខណៈទូទៅ

-ស្ពៃក្ដោបចែកចេញជា៣ប្រភេទទៅតាមពណ៌នៃស្លឹក: ពូជស្លឹកពណ៌ស្វាយ ពណ៌ស និង ពណ៌ក្រហម ។

-គ្រាប់ពូជមានភាពល្អិតៗ ទំងន់២០០-៣០០គ្រាប់/ក្រាម។ គេប្រើគ្រាប់ពូជចំនួន៣៥០-៤០០ក្រាម/ហិកតា ។



## ២.អំពីបរិស្ថាន

**ក-ដី:** ដីដែលល្អសម្រាប់ដំណាំនេះ គឺដីល្បប់តាមមាត់ទន្លេ ដីក្រហមខ្ពង់រាប ដីខ្មៅ និង ដីពណ៌ត្នោត ។

**ខ-សីតុណ្ហភាពនិងពន្លឺ:** ដំណាំប្រភេទនេះ គឺត្រូវការពន្លឺសម្រាប់ការដុះលូតលាស់ និង ចេញផ្កា ។

ដំណាំស្ពៃក្ដោបដុះលូតលាស់បាននៅសីតុណ្ហភាពទាបបំផុតគឺ ១០-១២ អង្សាសេ និងខ្ពស់បំផុត ២៥-៣០ អង្សាសេ។ ប៉ុន្តែសម្រាប់ការដាំ

ជុះ និង ទទួលបានទិន្នផលខ្ពស់គឺចន្លោះពី១៥-២៥ អង្សាសេ។

**គ-សំណើមបរិយាកាស:** សំណើមបរិយាកាសសមស្របគឺចន្លោះពី ៧០-៨០% (លើសពី៨៥%នឹងធ្វើឱ្យ រលាកក្តោប ឬ រលួយគល់) ។

## ៣.បច្ចេកទេសដាំដុះ

ក-ការជ្រើសរើសរដូវ: គឺពីខែតុលា ដល់ ខែកុម្ភៈ ដែលអាកាសធាតុត្រជាក់។ សីតុណ្ហភាព-ពន្លឺសមស្រប

ខ-ការរៀបចំដី:

-រៀបចំភ្ជួរនៅពេលដីស្ងួត-ស្រស់ទឹក

-ហើយរាស់ប្រមូលយកស្មៅឬកាកសំណល់ផ្សេងៗចេញឱ្យស្អាត

-ទើបភ្ជួរលើកទី១ រួចហាលដី ៣-៥ថ្ងៃ ទើបភ្ជួរលើកទី២ ( បើដីខ្វះជាតិកំបោរស អាចបាចកំបោរស ២៥០-៣៥០ គក្រ ក្នុង១ហិកតា ហើយរាស់លប់ទៅក្នុងដី )

-ភ្ជួរនិងរាស់ ២-៣ដង ឱ្យបានជ្រៅ ឱ្យខ្យល់ចេញចូលបានល្អ និងរក្សាសំណើមដីបានយូរថ្ងៃ។

គ-ការបណ្តុះកូន:

-ភ្ជួរដីឱ្យផុសល្អយកស្មៅចេញ រួចហាលដីឱ្យស្ងួត

-ធ្វើដីឱ្យម៉ត់ រួចបាចកំបោរស ២៥០ក្រាម ក្នុង២០ម$^{២}$

-លើករងទទឹង ១ម៉ែត្របណ្តោយ១០ម៉ែត្រ (រដូវវស្សារងត្រូវមាន

កំពស់១៥-២០សង្ទីម៉ែត្រ)

-បាចដីកំបុស្ដ៏ពីលើរង ហើយរាស់លប់កប់ទៅក្នុងដី (ហាមប្រើដីដែលមិនទាន់ពុកផុយល្អ)

-សាបគ្រាប់ពូជ ៧-១០ក្រាម ក្នុង១០ម$^{២}$

-រួចយកចំបើងគ្របពីលើរងឱ្យក្រាស់ល្មម រួចស្រោចទឹកឱ្យជោគ

-ស្រោចទឹក២ដង ក្នុង១ថ្ងៃ(ព្រឹកនិងល្ងាច)

-ក្រោយសាប២ថ្ងៃ ត្រូវបើកគំរបទាំងនោះចេញ ហើយគ្របជំនួសដោយសំណាញ់ពណ៌ខ្មៅក្រឡាញឹកឱ្យជិត(ការពារពពួកសត្វល្អិតចង្រៃផ្សេងៗ)

-កូនស្ពៃក្ដោបអាយុ២៥-២៨ថ្ងៃ (ស្លឹក ៣-៤ កំពស់ ៨-១០សម) អាចដកយកទៅដាំបាន



រោងបន្ទុំ និងបណ្ដុះកូនបន្លែ

ឃ-របៀបដាំដុះ

-លើករងកំពស់១៥-២០សម (នៅរដូវវស្សា) ទទឹងរង១ម៉ែត្របណ្ដោយ១០-១៥ម៉ែត្រ (ដីជំរាលត្រូវលើករងទទឹងជំរាល)

-កាប់រណ្តៅលើរងជា២ជួរ ចន្លោះជួរ៧០សង្ទីម៉ែត្រ ចន្លោះរណ្តៅ ៥០-៦០សង្ទីម៉ែត្រ

-ដាក់ជីលាមកសត្វ ឬជីកំប៉ុស្តិ៍ ដែលពុកផុយល្អទៅក្នុងរណ្តៅ (១៥-២០តោនក្នុង១ហិកតា) ច្របល់លាយឱ្យសព្វល្អរួចទើបយកកូនមកដាំ(១ដើមក្នុង១គុម្ព) ក្រោយពេលដាំត្រូវបន្តស្រោចទឹកក្នុង ១ថ្ងៃ/៣លើក រយៈពេល២-៣ថ្ងៃ។

**៦.ចំណាំ:**

១-ត្រូវផ្អាកស្រោចទឹកកូនស្ពៃ២ថ្ងៃ មុននឹងដកទៅដាំ ( ប៉ុន្តែនៅពេលរៀបដកត្រូវស្រោចទឹកឱ្យជោគ )

២-ត្រូវដាំនៅពេលថ្ងៃរសៀលដាំរួចស្រោចទឹកឱ្យជោគ។





ទិដ្ឋភាពចម្ការស្ពៃក្តោប

## ៤.ការថែទាំដំណាំ

**ក-ការស្រោចស្រព:** ដំណាំស្ពៃក្តោបត្រូវការទឹកជាប្រចាំ ប៉ុន្តែមិនឱ្យជោគជាំពេកនោះទេ ជាមធ្យម៨០-៨៥%។

-ការស្រោចដោយប៉ោត (ព្រឹក-ល្ងាច: ជាមធ្យម៧០-៨០លីត្រ ក្នុង ១៥ម)

-ការស្រោចដោយម៉ាស៊ីនគឺមួយថ្ងៃម្តង ជាពិសេសនៅពេលល្ងាច

-ការស្រោចដោយការបញ្ចូលទឹកផ្ទាល់ គេធ្វើឡើងតែលើដីរាបស្មើ និងនៅដំណាក់កាលស្ពៃវាក្តោបរួចហើយ។

***ដំណាំ នេះត្រូវការទឹកខ្លាំងក្នុងដំណាក់កាលក្រោយដាំ៤៥-៥០ថ្ងៃ***

**ខ-ការជ្រុំជ្រួយដីពូនគល់ និង កំចាត់ស្មៅ:**

-ត្រូវផ្អាកស្រោចទឹកចំនួន ១ថ្ងៃមុនពេលជ្រុំជ្រួយដី

-ត្រូវជ្រុំជ្រួយដីឱ្យផុស និងហាលដីមួយថ្ងៃទៀតឱ្យស្មៅងាប់

-រួចទើបស្រោចទឹកឱ្យជោគខ្លាំង

*ការជ្រុំជ្រួយដីធ្វើឡើង២លើក លើកទី១:១០-១៥ថ្ងៃក្រោយដាំ និង លើកទី២: ៣៥-៤០ថ្ងៃក្រោយដាំ បន្ទាប់មកគេមិនជ្រុំជ្រួយដីទៀតទេ គឺគ្រាន់តែសំអាតស្មៅតែប៉ុណ្ណោះ។*

**គ-ការប្រើប្រាស់ជី:**

ការដាក់ជីគឺត្រូវបែងចែកជាច្រើនដំណាក់កាលដូចខាងក្រោម:

☟ទ្រាប់បាត:

-ប្រើជីធម្មជាតិ ឬ ជីកំប៉ុស្តិ៍ពី៣០០គ.ក្រ/១០០ម$^{២}$

-ជីដេ-អា-ប៉េ(D-A-P) ១៨-៤៦-០០: ១គ.ក្រ/១០០ម$^{២}$

-ជីប៉ូតាស្យូម($K_{2}O$) ០០-០០-៦០: ១គ.ក្រ/១០០ម$^{២}$

-ជីផេះចំនួន៥០គ.ក្រ/១០០ម$^{២}$

☞ជីបំប៉ន:

-ប្រើជីអ៊ុយរ៉េ៣លើក:

**លើកទី១:**ក្រោយដាំ១៥ថ្ងៃ ដាក់ជី៦០០ក្រ/១០០ម$^{២}$

**លើកទី២:**បន្ទាប់ពីលើកទី១:១៥ថ្ងៃ ដាក់ជី៦០០ក្រ/១០០ម$^{២}$

**លើកទី៣:**បន្ទាប់ពីលើកទី២:១០ ឬ ១៥ថ្ងៃ ដាក់ជី៨០០ក្រ/១០០ម$^{២}$។

-ប្រើជីកំប៉ុស្ដិ៍ទឹកស្រោចតាមគល់ រួចស្រោចទឹកធម្មតាតាមក្រោយ( ក្រោយដាំ៥-៧ថ្ងៃ, ១៨-២០ថ្ងៃ, ៣០-៣៥ថ្ងៃ និង៤៥-៥០ថ្ងៃ )។

-ឬដាក់ជី១៥-១៥-១៥:២០ក្រាម/ម$^{២}$ បន្ទាប់ពីស្ទូង១៥ថ្ងៃ

-ដាក់ជីហ្វូសស្វាតអាម៉ូនីញ៉ាក់៥០ក្រាម/ម$^{២}$ ឬដាក់ជី១៥-១៥-១៥:២០ក្រាម/ម$^{២}$ នៅពេលចាប់ផ្ដើមក្ដោប និងបន្ថយទឹក។

## ៥.សត្វល្អិតចង្រៃបំផ្លាញលើដំណាំស្ពៃក្ដោប

### ក-សត្វឆាភក្ខ


ពង


កូនដង្កូវស៊ីឫស


ដឹកឌឿ


ទាកគូពេញវ័យ

## ខ-ដង្កូវយោលទោង



ពង | កូនដង្កូវ | ដឹកឌឿ | មេអំបៅ

## គ-ដង្កូវហ្វូង ឬ ដង្កូវរយ



ពង | កូនដង្កូវ | ដង្កូវពេញវ័យ | មេអំបៅ

## ឃ-ដង្កូវស៊ីរូងបណ្ដូលស្ពៃ



ពង | កូនដង្កូវ | ដង្កូវពេញវ័យ | មេអំបៅ

## ង-ដង្កូវកាត់ខ្លង



ពង | ដង្កូវទើបញាស់ | ដង្កូវពេញវ័យ | ដង្កូវចំណាស់ | ដឹកឌឿ

**ច-ចៃ**



វិធានការការពារ និង កំចាត់

កំចាត់សត្វស៊ីដំណាំ ដោយប្រើថ្នាំផ្សំពីរុក្ខជាតិ, ថ្នាំកសិកម្មនិងការកំចាត់តាមបែបមេកានិចអាចជួយឱ្យការដាំដុះលូតលាស់បានល្អប្រសើរ និងរក្សាសត្វមានប្រយោជន៍ដូចជា ពីងពាង កន្ទុំរុយ ខ្ទូតដី សត្វកន្ទុយពីរ។

## ៦.ជម្ងឺលើដំណាំស្ពៃក្ដោប

ក-ក្រុមជម្ងឺ:

-ជម្ងឺពកឫស

-និងជម្ងឺរលួយឫស...

ខ-ក្រុមជម្ងឺបាក់តេរី:

-ជម្ងឺរលួយទន់

-និងជម្ងឺរលួយខ្មៅ...

គ-ក្រុមវីរុសៈ បណ្តាលពីពពួកចៃរោមចម្លងជម្ងឺវីរុស (ធ្វើឱ្យស្លឹករួញស្លឹក)

វិធានការការពារ និងកំចាត់ជម្ងឺ

-ជម្ងឺផ្សិតៈ បន្ថយការស្រោចទឹក ទុកដីឱ្យស្ងួត ដកស្មៅឱ្យស្អាត បាចកំបោរស ត្រង់កន្លែងកើតជម្ងឺ។

-ជម្ងឺបាក់តេរីៈ បន្ថយការស្រោចទឹក ដកដើមកើតជម្ងឺចេញប្តូរមុខដំណាំ ផ្អាកការដាំដុះ ដុតសំលាប់មេរោគលើថ្នាលបណ្តុះ

-ជម្ងឺវីរុសៈ បាញ់ថ្នាំផ្សំពីរុក្ខជាតិសំលាប់ពពួកចៃ មមាចទ្រីប និងដកដើមទាំងនោះចោល ជ្រើសរើសពូជធន់ទ្រាំ។

## ៧.ការប្រមូលផល

ការប្រមូលផលត្រូវធ្វើឡើងតាមប្រភេទពូជៈ

-ពូជស្រាលពី៧០-៨០ថ្ងៃ

-ពូជកណ្តាលពី៨០-៩០ថ្ងៃ

-ពូជធ្ងន់មានអាយុកាលពី៩០-១១០ថ្ងៃ


ទិដ្ឋភាពប្រមូលផលដំណាំស្ពៃក្តោប

*មុនប្រមូលផលត្រូវផ្អាកស្រោចទឹក ៥-៧ថ្ងៃ* ដើម្បីឱ្យស្ពៃក្តោបណែនល្អ។ ពេលកាត់ត្រូវរក្សាសន្លឹកខៀវ៣-៤សន្លឹកព័ទ្ធជុំវិញក្តោប ដើម្បីរក្សាទុកឱ្យបានយូរក្នុងការដឹកជញ្ជូនទៅកាន់ទីឆ្ងាយៗ។ ទិន្នផលជាមធ្យមគឺនៅចន្លោះពី២៥-៣០តោន/១ហិកតា។

# ដំណាំត្រសក់ចំណារ

Cucumber

## ១.ស្ថានភាពទូទៅ



-ដំណាំត្រសក់មានប្រភពនៅប្រទេសឥណ្ឌា ក្រោយមកក៏រីករាលដាលទៅប្រទេសអេស៊ីប, ក្រិច, ចិន, ឥណ្ឌូនេស៊ី, ថៃ និង នៅទ្វីបអាមេរិក។

-ដំណាំត្រសក់ស្ថិតក្នុងលំដាប់គ្រួសារគូកូប៊ីតាសេ។

**ក.វីតាមីន និងសារធាតុរ៉ែ:** ក្នុងទម្ងន់ត្រសក់១០០ក្រាមមានដូចខាងក្រោម:

| | |
|---|---|
| ទឹក | ៩៦,៣ក្រាម |
| ប្រូតេអ៊ីន | ០,៨៨ក្រាម |
| ប្រេងខ្លាញ់ | ០,៥ក្រាម |
| ថាមពល | ១៣ គីឡូកាឡូរី |
| កាល់ស្យូម | ១០មីលីក្រាម |
| ផូស្វាត | ២៥មីលីក្រាម |
| ដែក | ១,៥មីលីក្រាម |
| វីតាមីនសេ | ៧មីលីក្រាម |



**ខ.សីតុណ្ហភាព:** ដំណាំប្រភេទនេះត្រូវការអាកាសធាតុក្ដៅមធ្យម

ចន្លោះពី១៨-៣០°C ហើយអាចដាំបានគ្រប់រដូវ ប៉ុន្តែរដូវសមស្របគឺរដូវប្រាំង( វិច្ឆិកា-កុម្ភៈ )។

## ២.បច្ចេកទេសដាំដុះ

**២.១-ពូជ:** ពូជជាកត្តាសំខាន់ក្នុងការកំណត់ទិន្នផល ពីព្រោះថាពូជមានលក្ខខណ្ឌផ្សេងៗគ្នា ហើយត្រូវបានគេបែងចែកជា៣ប្រភេទដូចខាងក្រោម:

ក.ពូជស្រាល:អាយុ៣៥-៤៥ថ្ងៃក្រោយដាំ (១០០គ្រាប់ស្មើ ២,៥-៤ក្រាម ) ជាប្រភេទត្រសក់បន្លា ឬ ត្រសក់ជ្រក់។

ខ.ពូជកណ្តាល: អាយុ៤០-៥០ថ្ងៃក្រោយដាំ ជាប្រភេទត្រសក់កសិករនិយមដាំតាមសួនបន្លែ វាផ្តល់ផលពី៦-៧តោន/ហិកតា។

គ.ពូជធ្ងន់: អាយុ៥០-៧០ថ្ងៃ ក្រោយដាំ (១០០គ្រាប់ស្មើ ៣,៥-៥,៥ក្រាម ) តម្រូវការពូជពី៣,៥ ទៅ ៥គីឡូក្រាម។

**២.២-ការជ្រើសរើស និង រៀបចំដី:**

ក.ការជ្រើសរើសដី: ត្រសក់ត្រូវការដីមានជីជាតិគ្រប់គ្រាន់សំបូរទៅដោយសារធាតុចិញ្ចឹម និងបន្ទុកខ្យល់គ្រប់គ្រាន់ គឺប្រភេទដីមាត់ស្ទឹង, បឹង, ទន្លេ និងដីល្បាយខ្សាច់មិនដក់ទឹក PHសមស្របចន្លោះពី ៦,៥-៧,៥ ។ កាលណា PH ទាបជាង ៤ ត្រូវផ្អាកការដាំត្រសក់រយៈពេល ១-២ ឆ្នាំ ត្រូវដាំដំណាំអំបូរសណ្តែក ដើម្បីកែលម្អដី។

ខ.ការរៀបចំដី:ត្រូវរាស់ប្រមូលយកស្មៅ និងដំណាំផ្សេងៗពីរដូវមុនចេញ ភ្ជួរហាលដីលើកទី១ឲ្យជ្រៅត្រឡប់ស្រទាប់ដីពីក្រោមឡើងលើ និងហាលដីឲ្យបានច្រើនសប្ដាហ៍ ក្នុងគោលបំណងបន្ថយនូវភ្នាក់ងារចម្លងជម្ងឺ និងសត្វល្អិត ព្រមទាំងឲ្យស្មៅចង្រៃងាប់ ជាពិសេសគឺប្ដូរទំរង់ដី និងពង្រាយជីជាតិ។ ការភ្ជួរនឹងត្រូវធ្វើឲ្យបាន២-៣លើកមុននឹងលើករងដាំដុះ។ ការលើករងសម្រាប់ដាំ គឺអាស្រ័យទៅលើវិធីដាំ និងជីជាតិរបស់ដី។ កាលណាដាំដោយដោតចំណារបញ្ឈរ ទទឹងរងត្រូវមានប្រវែង១២០ស.ម កំពស់រង ២៥-៣០ស.ម។ ប៉ុន្តែបើដាំឲ្យវារនៅលើដី ទទឹងរងមានប្រវែងពី៨០-១០០ស.ម តែការដាំតាមវិធីនេះ ត្រសក់ទទួលទិន្នផលទាប។ នៅក្នុងលក្ខខណ្ឌអាកាសធាតុក្ដៅ ដីរក្សាសំណើមគ្របដីមុនពេលដាំ ដើម្បីបន្ថយកំដៅដី ស្មៅរក្សាសំណើមបានយូរ និងធ្វើឲ្យដីធូរមិនហាប់ កាលណាដីហាប់បណ្ដាលឲ្យបន្ទុកខ្យល់មិនគ្រប់គ្រាន់ ប្រវែងឫសចាក់បានរាក់។

### ២.៣-វិធីសាស្ត្រដាំដុះមានពីររបៀប

២.៣.១ដាំដោយផ្ទាល់: មុននឹងដាំត្រូវយកគ្រាប់ពូជមកដាក់ហាលថ្ងៃអោយក្ដៅរយ:ពេល១-២ម៉ោង បន្ទាប់មកយកទៅត្រាំទឹករយ:ពេល៤-៥ម៉ោង បន្ទាប់មកត្រូវលាងគ្រាប់អោយស្អាតចំនួន៣-៤លើកមុនពេលផ្អាប់គ្រាប់ពូជ ។ ការផ្អាប់ត្រូវយកក្រណាត់ជ្រលក់ទឹកឱ្យ

ជោគយកមកខ្ចប់គ្រាប់នោះ ហើយកប់នៅក្នុងដីសើមៗរយៈពេល១យប់ ដាំក្នុងចន្លោះគុម្ព២៥ស.ម ចន្លោះជួរ ៦០ស.ម ជំរៅ ២-៣ស.ម ដាក់២-៣គ្រាប់ក្នុងមួយគុម្ព ហើយគ្របចំបើងខ្លីៗ ឬ ជីធម្មជាតិពុករលួយល្អពីលើ វិធីនេះគឺដាំឲ្យត្រសក់ឡើងតោងចំណារបញ្ឈរ ប៉ុន្តែការដាំឲ្យវារលើដីត្រូវប្រើចន្លោះជួរ៨០ស.ម ចន្លោះគុម្ព៥០ស.ម ៣-៤គ្រាប់ក្នុងមួយគុម្ពតែគ្រប់គុម្ពដូចគ្នា។ ក្រោយពីដាំភ្លាមៗ ត្រូវពិនិត្យមើលសំណើមដីកាលណាដីស្ងួតខ្លាំងត្រូវតែស្រោចទឹកក្រោយពីដាំ ហើយដើម្បីឲ្យត្រសក់ដុះស្មើគ្នាងាយថែទាំ។ ក្រោយដាំរយៈពេល៣-៤ថ្ងៃ ក្នុងលក្ខខណ្ឌអាកាសធាតុពេលថ្ងៃ ៣០°C និងពេលយប់ ១៨-២០°C ធ្វើឲ្យត្រសក់លូតលាស់លឿន។





ទិដ្ឋភាពកូនដំណាំត្រសក់

២.៣.២<u>ដាំដោយបណ្តុះកូន:</u>

-រៀបចំកន្ទោងបណ្តុះ (ស្លឹកចេកឬស្លឹកត្នោត) ឬ ត្រេ

បណ្តុះកូន។

-យកដីមានជីជាតិ(ដីដំបូក)១ភាគ ជីកំប៉ុស្ត៍ ជីលាមកគោពុកផុយ១ភាគ និងផេះអង្កាម១ភាគលាយជាមួយគ្នា ហើយយកទៅលីងឲ្យក្តៅបំផុតរួចទុកឲ្យត្រជាក់ទើបដាក់ចូលកន្ទោង។

-បណ្តុះតែមួយគ្រាប់ក្នុង១កន្ទោង តែកុំកប់ជ្រៅពេក

-ត្រូវគ្របសំណាញ់សត្វល្អិត និងធ្វើដំបូលគ្របអំពីសំណាញ់កាត់បន្ថយពន្លឺនៅរដូវក្តៅ។ នៅរដូវវស្សាត្រូវធ្វើដំបូលការពារទឹកភ្លៀង។ កូនដំណាំនៅតូចមិនត្រូវការពន្លឺ និងទឹកច្រើនពេកទេ។

-ស្រោចទឹក១ថ្ងៃមួយដង គឺស្រោចនៅពេលព្រឹក។

▹ការដាំកូនត្រសក់:

-ត្រូវដាក់កូនត្រសក់ឲ្យចំពន្លឺថ្ងៃចំនួន២ ទៅ៣ថ្ងៃមុនដាំដើម្បីឲ្យដើមរឹងមាំល្អ ហើយផ្សាំទៅនឹងអាកាសធាតុនៅខាងក្រៅ។

-កូនត្រសក់អាយុបាន៥ថ្ងៃ អាចយកទៅដាំបាន (អាស្រ័យការថែទាំកូន)

-ស្រោចទឹកកូនត្រសក់ឲ្យបានសើមល្មម នៅពេលព្រឹកទើបយកកូនត្រសក់ទៅដាំនៅពេលរសៀល

-ដកកូនពីកន្ទោង ឬ គ្រែដោយប្រុងប្រយ័ត្នបំផុតមិនត្រូវឲ្យដាច់ឫសកូនត្រសក់

-ចន្លោះគុម្ព និងចន្លោះជួរ៥០-៧០ស.ម។

## ៣-របៀបស្រោចស្រព

-ដំណាំត្រសក់ជាប្រភេទដំណាំត្រូវការទឹកជាប្រចាំ ប៉ុន្តែសំណើមដីមិនលើសពី ៥០-៧០%ឡើយ។ សេចក្ដីត្រូវការទឹកចែកចេញជា៣វគ្គគឺ៖

-វគ្គលូតលាស់ ៖ ចាប់ពីត្រសក់ដុះរហូតដល់ត្រសក់បោះដៃ និងមានផ្កាក្រពុំ វាត្រូវការសំណើមដីជាមធ្យមប្រមាណពី៥០-៦០% របៀបស្រោច ដោយបាញ់ទឹកលើ ល្អជាងការស្រោចដោយបញ្ចូលតាមចន្លោះជួរ គឺ១ថ្ងៃម្ដង ឬ២ដង ទៅតាមប្រភេទដី និងអាកាសធាតុ បរិមាណទឹកក្នុងវគ្គនេះមានប្រមាណពី១៤០០-១៦០០ម$^{៣}$/ហិកតា។

-វគ្គបន្តពូជ និងផ្លែ ៖ ចាប់ពីត្រសក់មានអាយុពី១៥ថ្ងៃឡើងទៅ វានឹងមានផ្កាឈ្មោលចេញតាមថ្នាំង ប៉ុន្តែមិនទាន់រីក វគ្គនេះវាត្រូវការសំណើមដីពី៦០-៧០% គឺជាវគ្គដែលត្រូវការទឹកច្រើនជាងគេរហូតដល់ត្រសក់មានអាយុ៣០-៤០ថ្ងៃក្រោយដាំ ប៉ុន្តែការស្រោចដោយបញ្ចូលតាមចន្លោះមួយអាទិត្យ២-៣លើកលើរងជាការល្អ ព្រោះការស្រោចដោយបាញ់ទឹកពីលើធ្វើអោយប៉ះពាល់ដល់ការបន្តពូជ បរិមាណទឹកសរុបក្នុងវគ្គនេះមានពី១៨០០-២០០០ ម$^{៣}$/ហិកតា។

-វគ្គចេញផ្លែ ១០០% (Fruit maturity) ចាប់ពីការប្រមូលផលបាន ១-២លើក ត្រសក់ត្រូវការសំណើមដីទាបមកវិញ គឺពី ៥០-៦៥ %កាលណាការបញ្ចូលទឹកលើសពីនេះ ធ្វើឱ្យត្រសក់ចាប់ប្រែពណ៌ពីបៃតងទៅលឿង ជាការល្អបរិមាណទឹកពី១៤០០-១៦៥០ម$^{៣}$/ហិកតា (Tropieal Crop 1968).

## ៤-ដកស្មៅ និងជ្រុំជ្រួយដី

-ការជ្រុំជ្រួយដីត្រូវធ្វើឡើង នៅពេលត្រសក់មានសន្លឹកពិតចំនួន២ គឺនៅពេលទងរបស់វាលូតវែង (១០-១៥ថ្ងៃក្រោយដាំ) ត្រូវជ្រុំបំបែកដីសើរៗហើយកៀរយកដីពីបាតរងមកលប់គល់អោយជិត ក្នុងករណីដីដែលដុះស្មៅត្រូវដកយកស្មៅចេញមុនជ្រុំជ្រួយដី។ ចំពោះការដាំដោយគ្របនឹងកៅស៊ូខ្មៅ Black Plastic Mulching មិនចាំបាច់ជ្រុំជ្រួយឡើយ...........។ ការជ្រុំជ្រួយដីគឺប្រយោជន៍ធ្វើឲ្យដីធូរ ជ្រាបទឹកបានល្អ រក្សាសំណើមបានយូរ ធ្វើឲ្យមានខ្យល់ចេញចូលបានល្អ បន្ថយការលូតលាស់របស់ស្មៅ។

## ៥-ការដោតចំណារ

-តាមការពិសោធន៍ជាច្រើនឆ្នាំ នៅមជ្ឈមណ្ឌលដំណាំបន្លែអាស៊ី AVRDCតៃវ៉ាន់ និងនៅស្ថានីយ៍ក្បាលកោះ ការដោតចំណារឲ្យ និងការមិនដោតចំណារឲ្យទិន្នផលខុសគ្នាពីរ៣,៥-៤,០តោន/ហិកតា។ ដូចនេះ

ការដោតចំណារមានសារៈសំខាន់ជួយបង្កើនទិន្នផល និងបន្ថយការរាតត្បាតពីជម្ងឺ និងសត្វល្អិត។

-ការដោតចំណារត្រូវយកមែកឈើក្រៀមៗ គ្មានស្លឹក មកដោតបញ្ឈរក្បែរគុម្ពឲ្យញឹក ហើយចងឲ្យជាប់ ការពារការដួលរលំ គេធ្វើឡើងក្រោយពីដាំរយៈពេល ១០-១៥ ថ្ងៃ គឺក្រោយពីជ្រុំជ្រួយដី។



ការដោតចំណារត្រសក់

## ៦-ការប្រើប្រាស់ជី

-ដំណាំត្រសក់ក៏ដូចដំណាំឯទៀតដែរ វាត្រូវការសារធាតុចិញ្ចឹមចម្បងគឺអាស៊ូត(N) ផូស្វ័រ(P) និងប៉ូតាស្យូម(K)និងសារធាតុផ្សេងៗទៀតដូចជាCa, S, Fe, Bo។ល។ ប៉ុន្តែសារធាតុទាំងនោះវាត្រូវការទៅតាមដំណាក់កាលដូចជា: ដំណាក់កាលលូតលាស់ដើម ស្លឹក វាត្រូវការ

អាសូតច្រើនជាងគេ បន្ទាប់មកគឺធាតុប៉ូតាស្យូម ប៉ុន្តែផូស្វ័រវាត្រូវការបន្តិចម្តងៗ ចាប់ពីវគ្គកំណារកំណើតផ្កា បរិមាណក្នុងមួយវគ្គជីវិតត្រូវការតិចជាងគេ ដូចនេះការប្រើជីត្រូវដាក់ទៅតាមដំណាក់កាលរបស់វា:

-មុនពេលដាំ គេតែងដាក់ជីធម្មជាតិឲ្យបានច្រើនពី១៥-២០តោន/ហិកតា និងជីគីមីប្រភេទ១៥-១៥-១៥ ចំនួន១៥០គីឡូក្រាម ជីទាំងនោះត្រូវដាក់ទៅក្នុងបាតរណ្តៅហើយជ្រុំដីលប់ឲ្យជិតពីលើ ទើបធ្វើការដាំដុះតាមក្រោយ។

-ក្រោយពេលដាំរយៈពេល១០-១៥ថ្ងៃ គេត្រូវយកជីអាសូតសុទ្ធ(អ៊ុយរ៉េ)ចំនួន២៥-៣០គីឡូក្រាម មកលាយទឹកស្រោចចំគុម្ព បន្ទាប់មកស្រោចទឹកតាមក្រោយ។

-នៅក្នុងវគ្គត្រសក់ចេញផ្កា១០០%គេយកជីគីមីប្រភេទ១៥-១៥-១៥ ដដែលចំនួន១០០គីឡូក្រាម មកដាក់តាមចន្លោះគុម្ព ហើយលប់ដីឲ្យជិត បន្ទាប់មកស្រោចទឹកឲ្យជោគ។

## ៧-ជម្ងឺ និង សត្វល្អិត

### ក-អំពីជម្ងឺផ្សិត

**-ដំណាំត្រសក់រងការបំផ្លាញដោយជម្ងឺផ្សិតច្រើនប្រភេទ** ហើយគ្រប់វគ្គនៃដំណាំ ដូចជាវគ្គលូតលាស់ វគ្គបន្តពូជ និងវគ្គទុំនៃផ្លែ។

**-ជម្ងឺរលាកគល់កូនដំណាំ:** ដែលឲ្យឈ្មោះថា Damping off វាបង្ក

ឡើងដោយក្រុមផ្សិតជាច្រើន ដូចជា Phyrium species Rhizoctonia solani, Bacicola, Acremonium species Fusarium equiseti និងប្រភេទ ផ្សិតជាច្រើនទៀត រោគសញ្ញាគឺចាប់ផ្ដើមរលាកគល់ដំណាំក្នុងដំណាក់កាល៥-៧ថ្ងៃក្រោយដុះ ធ្វើឲ្យរលាកជាំគល់ ក្រោយមកក៏ចាប់ផ្ដើមដួលរលំ ហើយរីករាលដាលកាន់តែច្រើនឡើងៗ លើរងកូនដំណាំ។ លក្ខខណ្ឌគឺកូនដំណាំស្ទោក ជាប់មកជាមួយគ្រាប់ ដីថ្នាលសំណាបមានមេរោគ សំណើមដីខ្ពស់លើសពី ៧០% គ្មានខ្យល់អាកាសនិងពន្លឺគ្រប់គ្រាន់។









-**ជម្ងឺស្ងួតស្លឹកពណ៌ត្នោត:** បង្កឡើងដោយភ្នាក់ងារឈ្មោះ Collectorichum oriculare រោគសញ្ញា:ដំបូងស្លឹកត្រសក់ឡើងលឿងផ្ទាំងធំៗ ក្រោយមកទៅជាស្ងួត ហើយប្រែពណ៌ទៅជាត្នោតប្រផេះ ពីស្លឹកក្រោមឡើងមកលើ ធ្វើអោយស្លឹកដំណាំស្ងួតពីដើមមួយទៅមួយ ហើយរីករាលដាលយ៉ាងរហ័ស។

▹លក្ខខណ្ឌបំផ្លាញៈ នៅរដូវវស្សាច្រើនជាងរដូវប្រាំង បណ្តាលមកពីសំណើមខ្ពស់ អាកាសធាតុក្តៅ ចន្លោះគុម្ពញឹក ចំនួនដើមក្នុងគុម្ពលើសកំណត់ ពន្លឺមិនគ្រប់គ្រាន់ ខ្យល់អាកាសមិនល្អ។

**-ជម្ងឺរលួយឬសនិងស្ងួតបណ្តាលនៃដើមៈ** វាបង្កឡើងដោយភ្នាក់ងារឈ្មោះ Fusarium oxysporum រោគសញ្ញាៈ ក្នុងដំណាក់កាលកូនដំណាំខ្ចីៗធ្វើឲ្យស្វិតរញមតែមិនដួលដូច Damping off ឡើយ....។ ពេលដំណាំចំណាស់ គឺនៅពេលថ្ងៃក្តៅខ្លាំងធ្វើឲ្យរញមស្រពោន ពីមួយថ្ងៃទៅមួយថ្ងៃកាន់តែស្រពោនឡើងៗ ដើមរបស់ដំណាំស្ងួតបណ្តូលឬសរបស់វាប្រេះហើយជាំៗ។

▷លក្ខខណ្ឌបំផ្លាញៈជម្ងឺរស់ក្នុងដី និងទឹក ហើយវាចំលងពីចំការមួយទៅចំការមួយ ពីដើមមួយទៅដើមមួយដោយទឹក និងកាកសំណល់ដំណាំ។ អាកាស់ធាតុក្តៅ សំណើមដីខ្លាំងលើសពី ៧៥% ងាយនិងកកើត។

**-ជម្ងឺផ្សិតម្សៅលើស្លឹកៈ** Powdery mildew វាបង្កឡើងដោយភ្នាក់ងារឈ្មោះ Erysiphecichora cearum និង phaerotheca fuligena រោគសញ្ញាៈដំបូងសង្កេតឃើញលេចចេញចំណុចពណ៌លឿងតូចៗលើស្លឹក ក្រោយមកមានស្នាមម្សៅកញ្ចុំៗរាងរង្វង់ រយៈពេលតែ២-៣ថ្ងៃម្សៅនោះរីករាលដាលពេញស្លឹក ទាំងស្លឹកខ្ចីក៏ដូចស្លឹកចាស់ បន្ទាប់មក

បែកធ្វើអោយស្ព័រហុយចេញពីចំការ។

▷លក្ខខណ្ឌកកើត:ច្រើននៅរដូវប្រាំង ពេលអាកាសធាតុត្រជាក់ស្ងួត មេរោគចូលចិត្តរស់នៅតាមដើមឈើព្រៃនិងឈើហូបផ្លែរដូវភ្លៀងមិនធ្វើអោយមានលក្ខណ:ធ្ងន់ធ្ងរឡើយ។



ជម្ងឺផ្សិតម្សៅលើស្លឹក

**ខ-ជម្ងឺបង្កឡើងដោយវីរុស:**

-ជម្ងឺដែលបង្កឡើងដោយវីរុស មានច្រើនប្រភេទលើដំណាំត្រសក់ដូចជា:

▷**ជម្ងឺរួញស្លឹកក្តួរចុះក្រោម** ( Cucumber mosaic Virus ): ជម្ងឺប្រភេទនេះវាបង្កឡើងដោយ Mosaic Virus រោគសញ្ញាដំបូងវាលេចចេញនូវចំនុចខ្លះនៅលើស្លឹក គឺសភាពរួញជាពិសេសស្លឹកខ្ចីៗ ក្នុងដំណាក់កាលលូតលាស់ធ្វើឲ្យមិនរីកធំធាត់បាន ព្រមទាំងធ្វើអោយផ្លែពកៗ ក្រឡាៗ ហើយរឹងសំបក សាច់ត្រសក់គ្មានរសជាតិ វារីករាលដាលដោយក្រុមចៃ។

▹វិធានការការពារ និងកំចាត់: ជ្រើសរើសពូជគ្មានជម្ងឺពីមេបា កំចាត់ស្មៅឲ្យស្អាត និងការពារកុំឲ្យចៃបំផ្លាញ



ជម្ងឺវីរុស

▹**ជម្ងឺកោងស្លឹកឡើងលើ** ( Squash leaf Curl ): ជម្ងឺប្រភេទនេះ បង្កឡើងដោយមរោគ ដែលរស់នៅលើដើមនិងស្លឹកល្ពៅដែលឲ្យឈ្មោះថា Squash leaf Curl Virus

▹រោគសញ្ញា: ដំបូងលេចចេញនៅលើស្លឹក មានចំនុចពណ៌បៃតងចាស់ ចំកណ្តាលស្លឹក ក្រោយមកស្លឹកនោះមិនមានសភាពត្រង់ឡើយ គឺទៅជាក្រាស ហើយបៃតងចាស់ពេញលើផ្លែដែលកើត ក្រោយមកមានសភាពរួញៗ ផ្ទាំងៗ ហើយរមូរគែមស្លឹកឡើងលើស្ងួតគែមករណីកើតលើផ្លែ ធ្វើឲ្យក្ដិបត្រសក់ខ្ចីៗ ស្វិតគួចមានពណ៌លឿងវាបំផ្លាញលើប្រភេទដំណាំអំបូរត្រសក់ស្ទើរគ្រប់ប្រភេទ។

▹វិធានការ ការពារនិងកំចាត់: បាញ់ថ្នាំប្រឆាំងនិងការដុះគ្រាប់ស្មៅមុនពេលដាំដំណាំ ប្តូរពូជថ្មី ឬ ប្រភេទដំណាំផ្សេងពីដំណាំត្រសក់

ក្នុងអំបូរ Cucurbita Ceae ទុកដីចោលទំនេររយៈពេលមួយរដូវដាំឲ្យបានមុនរដូវរុយស មានវត្តមានច្រើនរួមផ្សំជាមួយវិធានការគីមី ដើម្បីកំចាត់រុយស នៅពេលមានវត្តមានដំបូង។



ជម្ងឺកោងស្លឹកឡើងលើ

▹**ជម្ងឺពករលោងផ្លែស្លឹកខាងលើ:** Squash Mosaic ជម្ងឺនេះវាបង្កឡើងដោយមេរោគឈ្មោះ Squash Mosaic Virus

-សញ្ញាបំផ្លាញ: ដំបូងលើកូនត្រសក់ ដែលទើបនឹងចេញស្លឹកទី១-២ពិនិត្យឃើញស្លឹកនោះមានស្នាមពពាលចន្លោះសសៃទ្រនុងស្លឹកនៃផ្លែស្លឹក ហើយមានពណ៌បៃតងភ្លាវ សញ្ញាប្រហែលទៅនឹងកង្វះអាសូតដែរ ប៉ុន្តែត្រសក់អាចលូតលាស់បាន ធម្មតានៅពេលត្រសក់ចេញផ្កាស្លឹកត្រសក់លេចចេញសញ្ញាដូចធ្មេញរណានៅគែមស្លឹក ហើយផ្លែស្លឹកមានសភាព ដោរៗពកៗ ផ្ទាំងមានពណ៌បៃតងរលោងក្រាស នៅលើផ្លែពកៗ ក្រឡាៗសំបកក្រាស តែផ្លែអាចធំបង្គួរ ប៉ុន្តែក្រោយមកត្រសក់លែងផ្លែ។

-វិធានការការពារនិងកំចាត់: ជ្រើសរើសពូជមេបាកុំឲ្យកើតជម្ងឺនេះមានប្រសិទ្ធិភាពខ្ពស់ជាងគេ។

**គ-ជម្ងឺបង្កឡើងដោយបាក់តេរី:** Verticillium Wilt

-ជម្ងឺនេះបង្កឡើងដោយក្រុមបាក់តេរី ដែលរស់នៅក្នុងដីជាពិសេសបាក់តេរី២យ៉ាងគឺ Verticillium dahliae និង Verticillium albo-atrum វារស់នៅគ្រប់ទីកន្លែង ជាពិសេសកន្លែងដែលមានអាកាសធាតុក្ដៅ។

-សញ្ញាបំផ្លាញ:ជម្ងឺនេះតែងតែរាតត្បាតលើគ្រប់ដំណាំក្នុងអំបូរ Cucurbits Cucurbita សញ្ញាដំបូងលេចចេញនូវភាពរញមស្រពោនហើយស្លឹកប្រែពណ៌ទៅជាលឿង ជាពិសេសស្លឹកដំបូងរបស់ដំណាំ។ក្រោយមកស្លឹកប៉ែកខាងលើទៅជាពណ៌លឿងទាំងអស់ ហើយស្ងួតក្រោយមកដើមក៏ចាប់ផ្ដើមបញ្ឈប់ការលូតលាស់ ពេលនោះសាច់ដើមចន្លោះថ្នាំងឡើងជាំៗ ថ្នាំងរបស់វាមានសភាពស្ងួត។ កាលណាកាត់ដើមជាកង់ៗសង្កេតឃើញភាពជាំ តាមស្រទាប់សសៃសាច់ជារង្វង់ៗ ក្រោយមកជម្ងឺនេះ វាក៏ចាប់ផ្ដើមត្រឡប់ទៅក្នុងដីវិញបានច្រើនឆ្នាំ។

-លក្ខខណ្ឌកកើត: រីកសាយភាយផលប៉ះពាល់យ៉ាងសំខាន់នៃការឆ្លង និងកកើត គឺមេរោគចូលតាមរយៈឫស ក្រោយមកសីតុណ្ហភាពដីប្រែប្រួលពីក្ដៅទៅត្រជាក់ ឬ ត្រជាក់ទៅក្ដៅ វាជាលក្ខខណ្ឌបង្កមួយ

យ៉ាងសំខាន់ ជាពិសេសនៅវគ្គកំពុង ចេញផ្លែ ព្រោះវាជ្រកនៅក្នុងរុក្ខជាតិជុំវិញ និង ដី ជាលក្ខណៈងាយនឹងកើត បច្ចុប្បន្នត្រសក់ធ្វើឲ្យមានការខូចខាតយ៉ាងច្រើន នៅតំបន់ដីព្រៃខ្ពង់រាប។

-វិធានការការពារនិងកំចាត់: នៅប្រទេសកសិកម្មជឿនលឿន គេប្រើប្រេងពុលដែលឲ្យឈ្មោះថា Soilfumigation or Slar Sterilization បញ្ចូលទៅក្នុងដីទទួលប្រសិទ្ធិភាពល្អ ឬប្រើពូជធន់ទ្រាំទៅនឹងលក្ខខណ្ឌកកើតនៃជម្ងឺនេះ ។

## ៨-សត្វល្អិតសំខាន់ៗលើដំណាំត្រសក់

មានសត្វល្អិតចង្រៃជាច្រើនប្រភេទ ដែលបំផ្លាញដំណាំក្នុងនោះមានសត្វល្អិតជាភ្នាក់ងារបង្ករោគ និងសត្វល្អិតបំផ្លាញផ្ទាល់។ សត្វល្អិតជាភ្នាក់ងារបង្ករោគមាន:

-ចៃបៃតង Green peach aphid វារោមជញ្ជក់ស្លឹកធ្វើអោយត្រសក់រួញស្លឹកហើយខ្សួរចុះក្រោម។

-មមាចជញ្ជក់ស្លឹក Leaf hopper វាមាន២ប្រភេទ មាឌតូចនិងមាឌធំ តែងជញ្ជក់ស្លឹក ធ្វើឲ្យត្រសក់ស្ងួតគែមហើយកោងស្លឹកឡើងលើ។

-រុយស White fly រុយប្រភេទនេះមានមាឌតូចៗ ពណ៌ស ហើយមើលនឹងភ្នែកទទេស្ទើរមិនឃើញ គេអាចសង្កេតវាបានត្រូវពនិត្យមើលក្រោមស្លឹក នៅពេលថ្ងៃក្តៅ។ ពពួកសត្វទាំងនេះក្រោយពីបំផ្លាញហើយ

តែងតែចម្លងនូវជម្ងឺវីរុស ហើយអាចចម្លងពីចំការមួយទៅចំការមួយបានយ៉ាងងាយ។

-អណ្តើកមាសពណ៌លឿង Cucurbit leaf beetle វាស៊ីស្លឹកកូទីឡេដុង ត្រួយខ្ចី ផ្កាញី និងផ្កាឈ្មោល រំខានដល់ការលូតលាស់យ៉ាងខ្លាំង។

-ដង្កូវកាត់ដើម Black cutworm ដង្កូវប្រភេទនេះច្រើនលាក់ខ្លួននៅក្នុងដីពេលថ្ងៃ ចេញកាត់ដើមគ្រសក់នៅពេលយប់ លក្ខណៈបំផ្លាញក្នុងវគ្គកូនសំណាប Young Seedling ។

-ដង្កូវហ្វូងស៊ីផ្លែ និងស្លឹក Beet armyworm ដង្កូវប្រភេទនេះតែងតែស៊ីស្លឹក ផ្កា ផ្លែខ្ចីៗ ធ្វើឲ្យបាត់ទិន្នផលយ៉ាងច្រើន ព្រោះការបំផ្លាញរបស់វាលក្ខណៈជាហ្វូង។

-ដង្កូវមូរស្លឹក Leaf folder worm វាតែងតែជ្រកលាក់ខ្លួន និងស៊ីបំផ្លាញត្រួយគ្រសក់ខ្ចីៗក្នុងវគ្គលូតលាស់ ប៉ុន្តែនៅក្នុងវគ្គបន្តពូជវាធ្វើឲ្យជួបបញ្ហាយ៉ាងខ្លាំង ព្រោះវាស៊ីផ្តាច់ថង់លំអងផ្កាឈ្មោល និងផ្កាញីនៅពេលផ្ការីក(ម៉ោង៧-១០ព្រឹក) ។

ដើម្បីការពារទៅនឹងកត្តាចង្រៃទាំងនេះ គេត្រូវអនុវត្តវិធីសាស្រ្តច្រើនយ៉ាងដូចជាជ្រើសរើសរដូវ ផ្លាស់ប្តូរមុខដំណាំ ជ្រើសរើសពូជធន់ទ្រាំ រៀបចំដីឲ្យបានត្រឹមត្រូវ សំអាតស្មៅក្នុងចំការ ជាពិសេសគ្រប់គ្រងវត្តមានសត្វល្អិតមុនពេលវាពេញវ័យ បន្ទាប់មកអនុវត្តវិធានការគីមីដើម្បី

កំចាត់។

## ៩-ការប្រមូលផល

-ការប្រមូលផលបន្លែ គឺធ្វើឡើងក្រោយពីការដាំរយៈពេលខុសៗគ្នាទៅតាមប្រភេទពូជ អាស្រ័យទៅនិងសេចក្តីត្រូវការដូចជាៈ

-ពូជស្រាល គេអាចប្រមូលផលដំបូងក្រោយពីដាំរយៈពេល ៣៥-៤០ថ្ងៃ គឺបេះផ្លែដោយយកកន្ត្រៃកាត់ត្រឹមទងនៃផ្លែ ហាមប្រឡេះយកតែផ្លែបណ្តាលឲ្យផ្លែត្រសក់ឆាប់ប្រែពណ៌ក្រហម ប្រភេទពូជនេះទិន្នផលមធ្យមចន្លោះពី៨-១០តោន/ហិកតា។

-ពូជកណ្តាល គេអាចប្រមូលផលដំបូងក្រោយពីដាំរយៈពេល៤៥-៥០ថ្ងៃ។ ការបេះគឺកាត់យកផ្លែដូចជាត្រសក់ឯទៀតដែរ ការបេះយកផ្លែស្រស់ពី៥-៧លើក ហើយទិន្នផលមធ្យម១០-១២តោន/ហិកតា។

-ពូជធ្ងន់ គឺធ្វើការប្រមូលផលបានច្រើនលើក ពី ៥-១០ លើក ហើយទិន្នផលមធ្យម ១០-១៥ តោន/ហិកតា។





# ដាំណាំសាលាដ៍ហ្សង

## ១.ស្ថានភាពទូទៅ




សាលាដ៍ហ្សង ជារុក្ខជាតិមួយបែបមានដុះដោយឯកឯង និង ដោយការដាំនៅទ្វីបអឺរ៉ុប និងនៅអាមេរិក។ ភាគច្រើនរុក្ខជាតិនេះ ច្រើនមានដុះតាមមាត់អូរ ជ្រោះនិងទីដែលមានទឹកលិច ហើយហូរតិចៗផង។ សាលាដ៍ហ្សងមានឈ្មោះវិទ្យាសាស្ត្រហៅថា Nasturtium Officinale L. បច្ចុប្បន្នត្រូវគេដាំច្រើននៅភាគខាងលិចទ្វីបអាស៊ី និង នៅប្រទេសមួយចំនួនទៀតក្នុងតំបន់ត្រូពិក ដូចជាប្រទេសម៉ាឡេស៊ី ឥណ្ឌា ឥណ្ឌូនេស៊ី ហ្វីលីពីន វៀតណាម និងនៅភាគខាងជើងទ្វីបអាហ្វ្រិក។



សាលាដ៍ហ្សង ជារុក្ខជាតិដែលសំបូរដោយ:

-កាល់ស្យូម(៦៤ មីល្លីក្រាម)

-ដែក (១.១ មីល្លីក្រាម)

និងមានវីតាមីនអា, សេ ព្រមជាមួយសារជាតិរ៉ែមួយចំនួនផ្សេងទៀត។

## ២.លក្ខណៈជីវសាស្ត្រ

សាលាដ៍ហ្សងមានសណ្ឋានខ្ចី ផុយ និង ទន់ ដើមរបស់វាមានប្រវែងពី២០សង្ទីម៉ែត្រ ដល់ ៦០សង្ទីម៉ែត្រ ចន្លោះថ្នាំងពីមែកស្លឹកមួយ

ទៅមែកស្លឹកមួយទៀតមានប្រវែងពី០១ដល់០៥សង្ទីម៉ែត្រ រុក្ខជាតិនេះមានចំណុចខ្លាំងទៅលើកត្តាអាកាសធាតុ និងសំណើមនៅក្នុងខ្យល់។ តាមគល់មែករបស់វាមានដុះចេញជាខ្នែងមួយៗ ស្មើរគ្រប់ផាងទាំងអស់។ មែក ឬ ផាងរបស់ស្លឹកមានដុះស្លឹកបីទៅប្រាំបួនស្លឹក ដែលនៅចុងគេមានទំហំធំជាងគេ ស្លឹកទាំងឡាយរបស់វាសឹងមានរាងមូល មានពណ៌ខៀវចាស់ ឯចំណែកគែមរបស់ស្លឹកវិញមានសណ្ឋានដូចជាធ្មេញរណា។ រុក្ខជាតិនេះមានឫសស្វែដុះតាមគល់មែកត្រង់ផ្នែកណា ដែលមានប៉ះជាមួយដីឬទឹក ឫសទាំងនោះមានមុខងារបឺតស្រូបយកសារធាតុផ្សេងៗមកចិញ្ចឹមដើមរបស់វា បើគេកាត់យកមែកនេះមកដាំវាដុះក្លាយទៅជាដើមមួយផ្សេងដោយខ្លួនឯង ។

សាលាដ៏ហ្បុងចូលចិត្តដុះបំផុតត្រង់កន្លែងណា ដែលមានភក់ច្រើន វាអាចដុះនៅតាមទីដែលមានទឹករាក់ៗ ជម្រៅពី៤-៥ស.ម មានចរន្តទឹកហូរ នៅកន្លែងខ្លះដែលមានទឹកជ្រៅវាអាចដុះលូតលាស់វែង វារលើទឹកឬដុះងើបផុតពីទឹក។ សាលាដ៏ហ្បុងដុះលូតលាស់ល្អបំផុត បើសិនជាទឹកន្លែងដែលដាំវានោះមានសីតុណ្ហភាពត្រឹម ១៥ ទៅ ២០ អង្សាសេ និងមាន



សាលាដ៏ហ្បុងដុះតាមលក្ខណៈធម្មជាតិ

សណ្ឋានដីខ្ពស់ជាងនីវ៉ូទឹកសមុទ្រ១០០០ម៉ែត្រឡើងទៅ។

ប្រភេទដី ដែលអាចដាំសាឡាដហុ្សងល្អបំផុតនោះត្រូវមាន PH របស់ដីក្នុងចន្លោះប្រាំ៦ ទៅ ៧ តែវាមិនអាចរស់ ឬដុះលូតលាស់បានជាមួយដីដែលមាន PH ទាប (ដីជូរមានអាស៊ីដច្រើន) ដីប្រៃ ឬជាប្រភេទដីខ្សាច់ឡើយ ជាពិសេសការលូតលាស់របស់វានិងចុះអន់ខ្សោយនៅរដូវក្ដៅ។ វាចូលចិត្តទឹកន្លែងដែលមានកម្រិតសំណើមខ្ពស់បំផុត ដូច្នេះអ្នកដាំត្រូវមានប្រព័ន្ធបាញ់ទឹកបែបផ្សែងក្រូច ឲ្យបានច្រើនដងក្នុងមួយថ្ងៃយ៉ាងហោចណាស់ឲ្យបានដប់ទៅដប់ប្រាំដងដែរ ដោយរួមទាំងពេលយប់ផងបើមានធាតុអាកាសស្អុះស្អាប់ ឬស្ងួត។

## ៣.បច្ចេកទេសដាំដុះ

ការជ្រើសរើសពូជសម្រាប់ដាំ : ពូជសាលាដហុ្សងដែលមានដាំដុះនៅអាស៊ីយើងនេះ គឺជាពូជនៅក្នុងតំបន់ វាត្រូវស៊ាំជាមួយអាកាសធាតុនៅទីនេះ ធន់ជាមួយការបំផ្លាញរបស់សត្វដង្កូវ ធន់ជាមួយសីតុណ្ហភាពខ្ពស់ មានរសជាតិឆ្ងាញ់ និងអាចផ្ដល់ផលបានល្អគួរសមដែរ ប៉ុន្តែវាមិនសូវមានដើមធំល្អ ដូចនៅតំបន់ដែលមានអាកាសធាតុត្រជាក់នោះឡើយ។ ជារុក្ខជាតិដែលអាចដុះលូតលាស់បានគ្រប់រដូវកាល តែអ្នកដាំនៅក្នុងតំបន់អាស៊ីយើងនេះនិយមដាំវា នៅក្នុងរដូវរងា (រដូវត្រជាក់) ព្រោះជាពេលដែលមានខ្យល់ត្រជាក់ ធ្វើឲ្យវាអាចដុះលូតលាស់បាន

ល្អ ផ្តល់ទិន្នផលខ្ពស់ជាងរដូវផ្សេងទៀត។ ពូជដែលយើងជ្រើសរើសយកមកដាំ គឺត្រូវទិញពូជមកពីទីដែលគេមានដាំដំណាំនេះ ឬ ទិញមកពីទីផ្សាររើសមើលរកដើមណា




ដើមពូជសម្រាប់ដាំ

ដែលធំជាងគេ មាននៅជាប់ជាមួយឫសតិចតួច។

រៀបចំឡាំងឈើមួយដាក់ដីផុកៗសុទ្ធក្នុងឡាំងនោះ រួចយកដើមសាលាដហ្សង ដែលយើងបានរើសពូជមកនោះដាក់ដោត (ស្ទូង) ក្នុងដីភក់នោះ យកថង់ប្លាស្ទីកថ្លាមកគ្របពីលើឲ្យជិតយកវាទៅដាក់ត្រង់ទីដែលមានម្លប់ និងត្រជាក់។ ត្រូវធ្វើបែបនេះឲ្យបានច្រើនឡាំង បើសិនជាយើងត្រូវការវាច្រើន។ ជារៀងរាល់ថ្ងៃត្រូវបាញ់ទឹកស្រោចវាកុំឲ្យវាស្ងួតដើមឲ្យសោះ រហូតវាអាចចាប់ឫសថ្មី ដុះលាស់ចេញខ្នែងថ្មី ល្អត្រឹមត្រូវហើយ ទើបបានយើងរៀបចំកន្លែងសម្រាប់ដាំវា។ ត្រូវជ្រើសរើសយកទីតាំងណាមួយ ដែលមានសំណើមច្រើនសើមជានិច្ចគ្រប់រដូវកាល។ លើកភ្លឺ ឬ ទំនប់ឲ្យមានកំពស់៥០សង្ទីម៉ែត្រ មានបណ្តោយ ១៥ ទៅ ២០ ម៉ែត្រ ចន្លោះភ្លឺ ឬទំនប់ម្ខាងទៀតត្រូវមានគម្លាតមួយម៉ែត្រកន្លះពីគ្នា។ បើយើងមានបំណងដាំឲ្យបានច្រើន គួរធ្វើទំនប់បែបនេះឲ្យបានច្រើនជួរ

(ប្រឡាយ) ដោយទុកចន្លោះពីប្រឡាយមួយទៅប្រឡាយមួយទៀតចំនួន ៧០សង្ទីម៉ែត្រ ឬ ត្រឹម៥០សង្ទីម៉ែត្រក៏បាន។ នៅក្នុងប្រឡាយនេះត្រូវកើបយកដីភក់មកទីផ្សេងមកដាក់ឲ្យបានកម្រាស់៣០សង្ទីម៉ែត្រ ស្មើពាក់កណ្តាលជម្រៅរបស់ប្រឡាយ រួចប្រើរនាស់កាយកៀរភក់នោះឲ្យស្មើ បន្ទាប់មកបង្ហូរទឹកស្អាតដាក់បញ្ចូលឲ្យបានកំពស់២០សង្ទីម៉ែត្រពីផ្ទៃលើរបស់ភក់ ទឹកដែលបានបង្ហូរដាក់នេះវានឹងជ្រាបចូលក្នុងភក់ខ្លះ ហួតតាមខ្យល់ខ្លះ បន្ទាប់ពីរយៈពេលពីរ បីថ្ងៃក្រោយមក ត្រូវបូមទឹកបញ្ចូលបន្ថែមរហូតមានកំពស់២០សង្ទីម៉ែត្រជាថ្មី លើកទីពីរនេះត្រូវទុកឲ្យទឹកហួតអស់នៅសល់ត្រឹមតែ៥សង្ទីម៉ែត្របានហើយ។



ទិដ្ឋភាពចំការសាលាដីហ្សុង

ត្រូវរៀបចំធ្វើដំបូលគ្របពីលើប្រឡាយនេះ តាមបណ្តោយជួរប្រឡាយតាំងពីក្បាលទីរហូតចុងទី ដោយប្រើស្បៃប្រក់ដំបូលយកមកធ្វើ

ជាដំបូល ( ស្បៃប្រក់ដំបូលនេះមានលក់នៅផ្សារអូឫស្សី ក្នុង១ដុំមានប្រវែង ១០០ម៉ែត្រ ទទឹង ២ម៉ែត្រ តម្លៃក្នុងដុំ ៦៥ ដុល្លារ)។ នៅចន្លោះប្រឡាយនីមួយៗ យើងមិនចាំបាច់ធ្វើជាទំនប់ពីរក៏បាន ដោយប្រើបំពង់ទីបជ័រសម្រាប់ធ្វើជាប្រព័ន្ធបង្ហូរទឹកដាក់នៅតាមក្បាលប្រឡាយ ឯនៅចុងក្បាលប្រឡាយត្រូវបង្ហូរទឹកនោះចូលមកក្នុងអាងមួយ ទឹកក្នុងអាងនោះត្រូវបូមមកបង្ហូរតាមក្បាលប្រឡាយជាថ្មី ដោយមានបង្ហូរមកជាមួយនូវជីសរីរាង្គទឹក ដើម្បីជំនួយឲ្យដល់ការលូតលាស់របស់វា។

ដើម្បីជៀសវាងការចំណាយសម្រាប់បូមទឹកស្រោច គួរគប្បីប្រើម៉ូទ័របូមដើរដោយពន្លឺព្រះអាទិត្យ មានលក់ដោយមជ្ឈមណ្ឌលវៃឆ្លាតរបស់លោក គង់ ផារិទ្ធ នៅម្តុំខាងលិចផ្សារទួលគោក។ ការប្រើប្រាស់ប្រព័ន្ធនេះ យើងអាចបង្កើតឲ្យមានប្រព័ន្ធទឹកហូរតិចៗនៅក្នុងប្រឡាយដោយគ្រាន់តែប្រើប្រាស់ទឹកចាស់ដដែល តែត្រូវមានកូនអាងមួយសម្រាប់ចម្រោះទឹកនោះផង ដោយប្រើធ្យូងធ្វើជាគោលសម្រាប់សំអាតទឹកនោះ (ដាក់ធ្យូងចូលក្នុងអាងចម្រោះឲ្យបាន ៥០គីឡូក្រាម)។ ធ្វើប្រព័ន្ធស្រោចពីលើមួយ ដែលអាចបាញ់ចេញជាផ្សែងទឹកស្រោចពីលើដោយប្រើម៉ូទ័របូមប្រើពន្លឺព្រះអាទិត្យដូចគ្នា បើគ្មានលទ្ធភាពយើងអាចប្រើធុងមានផ្កាឈូកក៏បាន តែការធ្វើបែបនេះយើងត្រូវចំណាយពេលច្រើនណាស់ ព្រោះត្រូវស្រោចវារាល់មួយម៉ោងម្តងឯណោះ។ បន្ទាប់ពី

អ្វីៗបានរៀបចំរួចត្រឹមត្រូវស្រួលបួលហើយយើងអាចយកមែកសាលាដ៍ហ្សុង ដែលបានផ្សាំ នៅក្នុងឡាំងនោះមកដាំបានហើយ ដោយគ្រាន់តែប្រើរបស់អ្វីម្យ៉ាងចូកវាចេញពីក្នុងឡាំង ឬទម្លាយបាតឡាំងដាក់វាដាំតែម្តងក៏បាន តែត្រូវយកឡាំងចេញ។ នៅក្នុងរយៈពេលនេះយើងត្រូវយកចិត្តទុកដាក់ថែវាឲ្យបានម៉ត់ចត់បំផុត ជាពិសេសគឺទឹកសម្រាប់ស្រោចវាមិនត្រូវឲ្យដាច់ជាដាច់ខាត។ សាលាដ៍ហ្សុង អាចលក់បាននៅក្នុងទីផ្សារក្នុង១គីឡូក្រាម តម្លៃជិតមួយម៉ឺនរៀល គេលក់វាយចេញក្នុងតម្លៃមួយម៉ឺន ឬជាងមួយម៉ឺនរៀល។ នៅក្នុងទីផ្សារអ្នកត្រូវការសាលាដ៍ហ្សុងមានច្រើន ជារបស់កម្រក្នុងផ្សារ ជួនកាលថែមទាំងពិបាករកទិញទៀតផងវាជាបន្លែដែលមានសេចក្តីត្រូវការខ្ពស់ក្នុងទីផ្សារ។ សព្វថ្ងៃនេះសាលាដ៍ហ្សុងមានលក់នៅតាមផ្សារនានា ប៉ុន្តែវាមានដើមតូចល្អិតៗ។

## ៤.ការប្រមូលផល

យើងអាចប្រមូលផលវារាល់១០ថ្ងៃម្តង បើសិនជាការដុះលូតលាស់របស់វាល្អ ពេលប្រមូលផល គឺត្រូវកាត់យកតែផ្នែកខាងចុងប្រហែល១០ ទៅ ១៥សង្ទីម៉ែត្រ ក្រៅពីនេះគឺត្រូវទុកឲ្យវាលាស់ចេញជាត្រួយ និងមែកថ្មីតាមខ្នែងរបស់វា។

របៀបដាំសាលាដ៍ហ្សុង អាចដាំតាមវិធីច្រើនយ៉ាងណាស់ តែសម្រាប់ស្ថានភាពអាកាសធាតុក្តៅដូចនៅប្រទេសយើង គឺចាំបាច់

ណាស់ត្រូវមានដំបូលប្រក់ឲ្យវាជាដាច់ខាត បើពុំនោះទេការដុះលូតលាស់របស់វានឹងមិនសូវបានល្អឡើយ បើទោះបីជាវាដុះក៏មានដើមតូចល្អិតមិនសូវធំដែរ។ បើសិនជាអាចធ្វើបានត្រឹមត្រូវស្រួលបួល វានឹងជាមុខរបរមួយដែលអាចរកចំណូលបានច្រើនបង្គួរដែរ៕






# ខាត់ណាដើម

## ១.ស្ថានភាពទូទៅ




ដំណាំខាត់ណាដើម ឬ ខាត់ណាឈើ ត្រូវបានគេដាំដុះជាង២០០០ឆ្នាំមកហើយនៅលើតំបន់ជាច្រើន ក្នុងពិភពលោកដំណាំនេះមានប្រភពដើម នៅតំបន់ភាគខាងត្បូងប្រទេសអ៊ីតាលី វាត្រូវបានគេបែងចែកជា២ប្រភេទធំៗ គឺប្រភេទដើមខ្ពស់ស្លឹកក្រញាញ់លូតលាស់ក្នុងតំបន់ស៊ុបត្រូពិក និងប្រភេទស្លឹកលាត្រង់ធម្មតាត្រូវបានដាំដុះក្នុងតំបន់ត្រូពិក។

ខាត់ណាដើមជាប្រភពវីតាមីន និងរ៉ែផ្សេងៗតាមការសិក្សាស្រាវជ្រាវរបស់អង្គការFAOក្នុងឆ្នាំ១៩៧២អោយដឹងថាទំងន់១០០ក្រាម ដែលបរិភោគបានផ្តល់នូវអត្ថប្រយោជន៍យ៉ាងច្រើនដូចក្នុងតារាង:

តារាងអាហាររូបត្ថម្ភក្នុងទម្ងន់១០០ក្រាមដែលបរិភោគបាន

| ទម្ងន់/១០០ g | ថាមពល | ទឹក | ប្រូតេអ៊ីន | ប្រេង | កាបូនអ៊ីដ្រាត | Ca | P | Fe | V.A | V.C | $B_{1-2}$ |
|---|---|---|---|---|---|---|---|---|---|---|---|
| ខ្នាត | កាឡូរី | g | g | g | G | mg | mg | mg | µg | mg | mg |
| ដើម/ស្លឹក | ៣៥ | ៨៩ | ៣,០ | ០,៤ | ៦,៨ | ២៣០ | ៥៦ | ២,០ | ៧៥៤០ | ១១៥ | ០,១៣ |

## ២.បច្ចេកទេសដាំដុះ

### ក.រដូវកាលដាំដុះ

-រដូវប្រាំង: គេដាំនៅដើមខែវិច្ឆិកា និង ខែធ្នូ (រដូវរំហើយ រយៈពេលថ្ងៃខ្លីជាងយប់)

-រដូវវស្សា: គេដាំនៅខែមិថុនា និងខែកក្កដា ពីព្រោះអាកាសធាតុសមស្របមិនសូវមានសត្វល្អិត និង ជម្ងឺ

### ខ.ការជ្រើសរើសពូជ

-ពូជមានប្រវត្តិច្បាស់លាស់

-ពូជរក្សាក្នុងកំប៉ុង ឬថង់អាលុយមីញ៉ូមបិទជិត

-ប្រើប្រាស់ភ្លាមៗ ក្រោយពីហែកកញ្ចប់ ឬ កំប៉ុង

-ពូជធន់ទ្រាំជម្ងឺ និង សត្វល្អិត

-ពូជអាយុកាលលូតលាស់ខ្លី (តម្រូវការទីផ្សារ)

-មានដំណុះពី ៨៥-៩០%

### គ.ការជ្រើសរើស និងរៀបចំដី

<u>គ.១-ការជ្រើសរើសដី:</u> វាអាចដុះលូតលាស់បានលើដីច្រើនប្រភេទ ជាពិសេសលើដីល្បាប់មាត់ទន្លេ ដីក្រហម ដីខ្មៅ តែវាមិនលូតលាស់ល្អលើប្រភេទដីដែលមានល្បាយដីឥដ្ឋខ្ពស់ ព្រោះដីប្រភេទនេះមិនជ្រាបទឹក ដីដែលដក់ទឹកយូរដំណាំប្រភេទនេះមិនអាចលូតលាស់

បានល្អឡើយ។ Phសមស្របចន្លោះពី ៦,៥-៧,៥ សំណើមដីត្រូវមាន ៧០-៧៥%។ ល្អបំផុតដីដែលមានភាគរយដីឥដ្ឋខ្លះៗ ហៅថា Loamy soil ច្រើននៅតាមមាត់បឹង-ត្រពាំង ។

**គ.២-<u>ការរៀបចំដី:</u>** មិនត្រូវជ្រើសរើសយកដីដែលបានដាំដំណាំអំបូរស្ពៃពីរដូវមុនឡើយ ដីដែលល្អត្រូវបានដាំដំណាំឆ្លាស់ជាមួយនិងសណ្ដែក ពោត ស្រូវ។ នៅ រដូវប្រាំង យើងត្រូវភ្ជួរហាលដីរយៈពេល ៧-១០ថ្ងៃនិងរដូវវស្សាត្រូវភ្ជួរហាលដីរយៈពេល១០-៣០ថ្ងៃ ដោយដាក់បន្ថែមជីធម្មជាតិអោយបានច្រើន គេអាចបាចកំបោរសបន្ថែមចំនួន ២៥០-៣០០គ.ក្រ ក្នុង១ហិកតា(២ឆ្នាំម្ដង) ហើយភ្ជួរលប់ហាលដីឲ្យស្ងួត បំបែកដីអោយល្អិតប្រមូលយកកាកសំណល់ផ្សេងៗចេញ ហើយលើករងតាមក្រោយ ដែលមានទទឹងរង៨០-១០០ស.ម, កំពស់រង២០-២៥ស.ម បណ្ដោយរងតាមលទ្ធភាពដី ។ ក្រោយពីលើករងហើយ គេអាចយកជី ១៥-១៥-១៥ ឬ ជី DAP ចំនួន ១៥០-២០០ក្រាម បាចលើរងប្រវែង១៥ម។



ដំណាំខាត់ណាឈើ

**ឃ-ការដាំដុះ** ការដាំដុះដំណាំខាត់ណាដើម គេអាចធ្វើបាន២របៀបគឺ

-ការដាំដោយគ្រាប់ផ្ទាល់(សាប): គ្រាប់ពូជមុននិងយកទៅសាប គេត្រូវត្រាំទឹករយៈពេល៣-៤ម៉ោងសិន សម្រាប់ថ្នាលប្រវែង១៥ម ប្រើគ្រាប់ពូជចំនួនពី៧-១០ក្រាម គេសាបអោយរង្វើលនៅលើផ្ទៃរង បន្ទាប់មកបាចកំណាត់ចំបើងស្ងួតពីលើរួចស្រោចទឹកអោយជោគ ក្រោយមកគេយកថ្នាំផ្សិតចំនួនពី១០-១៥ក្រាម លាយទឹក១៨-២០លីត្រ បាញ់លើរងដែលបានសាប ដើម្បីការពារជំណុះខ្ទីៗរបស់កូនដំណាំ។ ក្រោយពីសាបបានរយៈពេល១០ថ្ងៃ គេត្រូវដកកូនរំលួសដោយទុកចន្លោះឃ្លាតរង្វើលៗ ប៉ុន្តែគេអាចសំរាំងដើមទុកអោយមានចន្លោះគុម្ព២០ស.មx២០ស.ម នៅពេលដករំលួសកូនលើកទី២ពី២៥-៣០ថ្ងៃ ក្រោយពីសាប។


កូនខាត់ណាឈើ

-ការដាំដោយកូនបណ្តុះក្នុងត្រេៈ ក្រោយពីសាបបណ្តុះកូនក្នុងត្រេ បានរយៈពេល១៨-២០ថ្ងៃ គេត្រូវយកកូនខាត់ណាទៅស្ទូងលើថ្នាលថ្មី ដែលបានរៀបចំជាស្រេចដោយដាំក្នុងចន្លោះគុម្ព និងជួរ២០ស.ម x ២០ស.ម ប៉ុន្តែជាការល្អគេត្រូវដាំនៅពេលល្ងាច ក្រោយពីដាំរួចរយៈពេល ពី២-៣ថ្ងៃ ត្រូវស្រោចទឹក១ថ្ងៃ៣ដង ដើម្បីបន្ថយភាពស្រពោន ដែលជាហេតុនាំ

អោយខាត់ណាពន្យាពេលលូតលាស់។

**ង-ការស្រោចស្រព:** ការផ្តល់ទឹកដល់ដំណាំគេត្រូវគោរពទៅតាមដំណាក់កាលលូតលាស់ ប្រភេទដី សីតុណ្ហភាព។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ នៅក្នុងវគ្គដុះពន្លកវាត្រូវការសំណើមដីសើម ហើយរក្សាបានយូរក្រោយពីវាដុះបាន១០០% រហូតដល់ការបង្កើតស្លឹកពិតលើកដំបូងចំនួន១-២សន្លឹក (១០-១៥ថ្ងៃ) វាត្រូវការសំណើមជាមធ្យម ប៉ុន្តែបន្ទាប់មកទៀត វាកាន់តែទាមទារនូវសំណើមដីកើនឡើងបន្តិចម្តងៗ រហូតដល់ស្លឹកខាត់ណាជាប់គ្នាគេនិងបន្ថយបរិមាណទឹកមកវិញ។ ក្នុងករណីដាំដោយស្ទូងកូន វាត្រូវការសំណើមដីកើនឡើងរហូត ចាប់ពីពេលស្ទូងដល់ស្លឹកជាប់គ្នា ទើបបន្ថយទឹកមកវិញ ។

**ច-ការជ្រុំជ្រួយដី:** គេធ្វើឡើងតាមវិធី ២ផ្សេងគ្នា

-សំរាប់ការដាំដោយសាបគ្រាប់គេជ្រុំជ្រោយដី២លើកគឺ: លើកទី១ក្នុងពេលដក រម្លស់កូនដំបូង និងលើកទី២ធ្វើឡើងក្នុងពេលដករម្លស់កូនលើកទី២ ដោយជ្រួយដីបន្តិចៗនៅគល់ ធ្វើអោយការលូតលាស់លឿន។

-សំរាប់ការដាំដោយស្ទូងកូន: គេធ្វើឡើងក្រោយពេលស្ទូងបាន៧-១០ថ្ងៃ គឺជ្រុំតែ១ដង។

**ឆ-ការដាក់ជី:** គេដាក់ជីច្រើនលើកទៅតាមលក្ខណ:នៃការដាំដុះ

-ស្រោចបំប៉នលើកទី១:ប្រភេទជីអ៊ុយរ៉េ ឬជីលាមកត្រាំទឹកក្រោយពីសាបបាន១២-១៣ថ្ងៃ ឬក្រោយពីស្ទូងបានពី៥-៧ថ្ងៃ ចំនួន៣០-៤០គ.ក្រក្នុង១ហិកតា ។

-ដាក់បំប៉នលើកទី២: ជី១៥-១៥-១៥ ចំនួន១០០-១៥០គ.ក្រ ក្នុង១ហិកតា ដាក់តាមចន្លោះគុម្ព ក្រោយពីសាបកូនបានពី ២០-២៥ថ្ងៃ ឬក្រោយស្ទូងកូនរយៈពេល១០-១៥ថ្ងៃ ។

-ការស្រោចបំប៉នលើកទី៣ និងទី៤: ក្រោយស្ទូងរយៈពេល៤០ថ្ងៃ និងចុងក្រោយបង្អស់៥០ថ្ងៃ ក្រោយស្ទូងចំនួន៤០គ.ក្រ ក្នុង១ហិកតា ដោយលាយជាមួយជីត្រាំ គឺគេយកជីអាចម៍មាន់ ឬកាកសណ្ដែកសៀងមកត្រាំជាមួយទឹកនោមអោយរលួយហើយយកជីនោះ១លីត្រលាយទឹកធម្មតាពី១៥-២០លីត្រ ស្រោចអោយជោគ ហើយស្រោចទឹកលាងតាមក្រោយ ។

## ៣-សត្វល្អិត និង ជម្ងឺ

**ក-ជម្ងឺសំខាន់ៗ:** ដំណាំប្រភេទនេះច្រើនរងការបំផ្លាញ ដោយជម្ងឺផ្សិតច្រើនប្រភេទដូចជា:




-ជម្ងឺពុកឫស: ដែលតែងតែកើតនៅលើកូនដំណាំតូចៗ ជាពិសេសធ្វើអោយរម្លួស់ឫស និង គល់ដែលធ្វើអោយកូន

ខាត់ណារលួយយ៉ាងច្រើនពិសេសនៅពេលមានភ្លៀងធ្លាក់ ឬសំណើមដីខ្ពស់។

-ជម្ងឺអុចលើស្លឹក: ជម្ងឺប្រភេទនេះ តែងតែធ្វើអោយស្លឹកខាត់ណាមានពណ៌លឿងដុំៗ ហើយខ្លោចត្រង់ចំណុចពណ៌លឿងនោះ ប្រែទៅជាពណ៌ត្នោត ធ្វើអោយផ្ទៃស្លឹកទាំងមូលប្រែពីពណ៌បៃតងទៅពណ៌លឿងទុំយ៉ាងរហ័ស ។



-ជម្ងឺ White spot : ជម្ងឺប្រភេទនេះ បំផ្លាញលើដំណាំយកស្លឹកជាច្រើន គឺធ្វើអោយស្លឹកប្រែទៅ ជាស្ងួត ហើយមានពណ៌សទាំងដុំៗ ជាពិសេសនៅចុងស្លឹកពីគែមមកកណ្តាល គែមស្លឹករមូរឡើងលើជម្ងឺនេះកើតពេលមេឃក្តៅខ្លាំង ។



✦ជម្ងឺទាំងនេះ គេអាចការពារដោយប្រើវិធីសាស្ត្រហាលដីអោយស្ងួតមុនពេលសាបគ្រាប់ ឬស្ទូង បន្ថយការស្រោចទឹក, ធ្វើដំបូលគ្របពីលើនៅរដូវក្តៅ និងជម្រើសចុងក្រោយប្រើថ្នាំកំចាត់ជម្ងឺផ្សិត។

## ខ-សត្វល្អិតសំខាន់ៗ

-ដង្កូវកាត់ដើម (Back cut worm)វាចូលចិត្តស៊ីបំផ្លាញដោយកាត់

ដើម ហើយជ្រកពួននៅក្នុងដីនៅពេលថ្ងៃ វាមានពណ៌ត្នោតក្រមៅ ។



-ដង្កូវហ្វូង (Beet army worm) វាស៊ីកាត់ស្លឹករុក្ខជាតិគ្រប់ប្រភេទ វគ្គមានដែលគួរអោយគ្រោះថ្នាក់គឺខែមករា, កុម្ភៈ និងខែមិនាមេអំបៅពងដាក់ពីក្រោមស្លឹកជាកញ្ចុំៗ ហើយមានស្បែគ្របការពារពីលើ ។





-ដង្កូវយោលទោង (Diamond back moth): ដង្កូវនេះគេចាត់ទុកប្រភេទសត្វល្អិតចង្រៃធ្ងន់ធ្ងរនៅលើពិភពលោកលើអំបូរស្ពៃ វាមានអាយុកាលសរុបពី១៣-២២ថ្ងៃ វាស៊ីបំផ្លាញដោយបកយកស្រទាប់ពណ៌ខៀវនៃស្លឹកបន្សល់ទុកភ្នាសស្តើងៗ។



-សត្វទាកគួរ (Flea beetle leaf) : សត្វប្រភេទនេះមេចំណាស់មានស្លាបរឹងភ្លឺរលោងតូចៗ លោតឬហើរជាក្រុមៗវាចូលចិត្តស៊ីបំផ្លាញពពួកស្ពៃក្តោប ខាត់ណាផ្កា ខាត់ណាដើម ស្ពៃ និង ឆៃថាវ។ រីឯដំណាក់កាលជាដង្កូវ គឺវារស់នៅក្នុងដីស៊ីបំផ្លាញឫសដំណាំប្រភេទដូចខាងលើការ

បំផ្លាញរបស់មេចំណាស់គឺអុចស្លឹកអោយធ្លុះរទុះៗ ធ្វើអោយដំណាំលូតលាស់យឺត។

## ៤-ការប្រមូលផល

គេអាចប្រមូលផលបាន ក្រោយពីដាំរយៈពេល៥៥-៦០ថ្ងៃ គឺនៅពេលវាជិតចេញផ្កា ឬចេញផ្កាក្រពុំតូចៗពេលនោះដើមរីកប៉ោងធំ គឺគេកាត់ដើមផ្នែកខាងលើដីត្រឹម ៤-៥ស.ម ហើយកាត់ស្លឹក៣-៤ចោល ផ្នែកខាងក្រោមដោយទុកស្លឹកខ្ចីៗ ចំនួន៥-៦សន្លឹកសំរាប់បរិភោគ ជាទូទៅ



# ដំណាំត្រប់

## ១-ស្ថានភាពទូទៅ




ត្រប់ជាដំណាំមួយ ដែលប្រជាជននៅលើពិភពលោកតែងបានស្គាល់ និងប្រើប្រាស់ធ្វើជា ម្ហូបអាហារប្រចាំថ្ងៃនិងមានប្រជាប្រិយ៍បំផុត ចាប់តាំងពីដើមសតវត្សទី១៦មកម្ល៉េះ។ តាមការស្រាវជ្រាវបានបង្ហាញថា ដំណាំត្រប់មានប្រភពកំណើតនៅតំបន់អាស៊ីដូចជា នៅប្រទេសចិន ឥណ្ឌា និងទ្វីបអាហ្វ្រិក។ ប៉ុន្តែក្រោយមកបានរីករាលដាលដល់ទ្វីបអាមេរិក និងពេញពិភពលោកជាពិសេសនៅតំបន់សីតុណ្ហភាពក្តៅ។ ដំណាំត្រប់មានច្រើនប្រភេទដូចជា: ត្រប់ពុតញង ត្រប់ស្រួយ ត្រប់ខា ត្រប់ពងមាន់ ត្រប់ក្រាំងរមាស ត្រប់សណ្តាយ ដែលមានផ្លែសំប៉ែត ឬមូល តែមានពណ៌ប្រផេះឬពណ៌បៃតង។ នៅប្រទេសកម្ពុជាយើងវិញ ត្រប់ជាប្រភេទបន្លែមួយយ៉ាងសាមញ្ញ ដែលប្រជាជនគ្រប់គ្នា តែងតែបរិភោគជាបន្លែក្នុងជីវភាពប្រចាំថ្ងៃ គេអាចដាំដុះវាជាលក្ខណ:ចំការធំៗតាមបណ្តោយទន្លេមេគង្គ និងតំបន់ផ្សេងៗទៀតច្រើនតែជាលក្ខណ:សួនបន្លែចម្រុះនៅតាមគ្រួសារ។

ការនិយមចូលចិត្តវាអាស្រ័យដោយរស់ក្លិន និងរស់ជាតិពិសេសរបស់វា....។

តាមការស្រាវជ្រាវរបស់អង្គការ FAO ក្នុងឆ្នាំ១៩៧២អោយដឹងថា ក្នុងទំងន់100g ដែលបរិភោគបានវាផ្តល់នូវសារធាតុចិញ្ចឹមសំរាប់សរីរាង្គកាយដូចខាងក្រោមៈ

*តារាងអាហាររូបត្ថម្ភទម្ងន់ **100g** ដែលបរិភោគបាន*

| ផ្នែកបរិភោគ | ថាមពល | ទឹក | ប្រូតេអ៊ីន | ប្រេង | កាបូនអ៊ីដ្រាត | Ca | K | P | Fe | $B_1$ | $B_2$ | V.C |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ខ្នាត | កាឡូរី | g | G | g | G | mg | mg | mg | mg | mg | mg | mg |
| ស្រស់ | 26 | 92 | 1,6 | 0,3 | 5,6 | 22 | 221 | 37 | 0,9 | 0,08 | 0,07 | 6,00 |
| ចំអិន | 23 | 93 | 1,0 | 0,1 | 5,6 | 43 | 00 | 17 | 0,5 | 0,04 | 0,04 | 5,00 |

## ២-លក្ខខណ្ឌអាកាសធាតុ និង ដី

### ២.១-លក្ខខណ្ឌអាកាសធាតុ

ដំណាំត្រប់គ្រប់ប្រភេទឆាប់ទទួលរងនូវអំពើប្រែប្រួល ពីអាកាសធាតុ ជាពិសេសនៅពេលសីតុណ្ហាភាពត្រជាក់សំណើមបរិយាកាសខ្ពស់ វាធ្វើអោយឥទ្ធិពលនៃការបន្តពូជប្រដាប់បន្តពូជញី (Overy) មិនទទួលយកលំអងផ្កាឈ្មោលក្នុងពេលវេលាដែលបង្កកំណើត។ ប៉ុន្តែសីតុណ្ហភាពត្រជាក់មធ្យម ហើយរយៈពេលវែងក្នុងរដូវដាំដុះ ធ្វើអោយត្រប់ទទួលបានជោគជ័យលើការងារផលិតកម្ម។ ប្រសិនបើសីតុណ្ហាភាពមធ្យមប្រចាំថ្ងៃចន្លោះពី២៥-៣៥អង្សាសេ ធ្វើអោយការដុះលូតលាស់

និងទិន្នផលទទួលបានខ្ពស់។ សីតុណ្ហាភាពចន្លោះពី ២០-២៧ អង្សាសេ នៅពេលយប់ធ្វើអោយគ្រាប់ត្រប់ពន្យាពេលដុះពន្លក។

### ២.២-លក្ខខណ្ឌដី

ត្រប់ជាដំណាំមួយ ដែលអាចដុះលូតលាស់បានលើដីស្ទើរគ្រប់ប្រភេទដូចជា៖ ដីល្បាយខ្សាច់ ដីខ្សាច់មធ្យម ដីកណ្ដោង ដីឥដ្ឋមធ្យម។ ប្រភេទដីដែលសមស្របសំរាប់ដំណាំនេះគឺ ដីឥដ្ឋល្បាយ និងដីល្បាយខ្សាច់ដែលមានPH ពី:៥,៥-៦,៨ ធ្វើអោយត្រប់ទទួលបានទិន្នផលខ្ពស់។ ម៉្យាងវិញទៀត វាអាចដុះលូតលាស់លើរយៈកំពស់រហូតដល់៨០០ម៉ែត្រ ធៀបនិងផ្ទៃសមុទ្រ។

## ៣-បច្ចេកទេសដាំដុះ

### ៣.១-រដូវកាលដាំដុះ

ត្រប់ជាប្រភេទដំណាំមួយដែលដុះលូតលាស់ពេញ១ឆ្នាំ ដោយមិនប្រកាន់រដូវ ក៏ប៉ុន្តែនៅពេលសីតុណ្ហាភាពឡើងខ្ពស់ធ្វើអោយត្រប់បន្ថយការចេញផ្កា ឬ ពេលសំណើមដីមិនគ្រប់គ្រាន់ធ្វើអោយត្រប់ផ្លែមិនបានវែង ហើយមានរសជាតិល្វីងខារ។

-រដូវប្រាំង: គេចាប់ផ្ដើមសាបកូននៅខែតុលា ហើយដាំខែវិច្ឆិកា ប្រមូលផលខែមករា ដល់ខែមិនា។

-រដូវវស្សា: គេដាំខែឧសភា ឬ ខែមិថុនា ប្រមូលផលនៅខែសីហា

និង ខែតុលា ជាពិសេសតំបន់ខ្ពង់រាប។

### ៣.២-ការជ្រើសរើសពូជ

-ពូជមានប្រភពច្បាស់លាស់ (ពូជបង្កាត់ Hybrid F1 ឬពូជក្នុងស្រុក )

-ពូជធន់និងជម្ងឺ សត្វល្អិត គ្រាប់ពូជត្រូវមានសុខភាពល្អ

-អាយុកាលលូតលាស់ខ្លី សមស្របតាមតំបន់ដាំដុះ និងតម្រូវការទីផ្សារ

-មានដំណុះចាប់ពី ៨៥-៩០%

-១ហិកតាប្រើពូជពី១៥០-២០០ក្រាម

### ៣.៣-ការរៀបចំដី

ដំបូងត្រូវរាស់ប្រមូលស្មៅ កាកសំណល់ដំណាំចាស់ៗយកទៅដុត ឬយកចេញពីចំការ បន្ទាប់មកភ្ជួរហាលដីរយៈពេល៥-៧ថ្ងៃ ដើម្បីឲ្យស្មៅងាប់ និងផ្តាច់ជីវិតពពួកសត្វល្អិតចង្រៃផ្សេងៗនៅក្នុងដី ក្រោយមកទើបរាស់បំបែកដីអោយម៉ត់និងកៀរដីអោយស្មើពី៣-៤លើក និងលើករងកម្ពស់ ២៥-៣០ស.ម ,ទទឹងរង ១២០ស.ម , បណ្តោយរងតាមផ្ទៃដីជាក់ស្តែង ។

### ៣.៤-ការដាំដុះ

ក-ការសាបគ្រាប់: គ្រាប់ត្រប់តូចល្អិត សំប៉ែត សំបករឹងហើយក្រាស់ មុននឹងសាបគ្រាប់ពូជ ត្រូវយកមកសំអាតជាមុន បន្ទាប់មកយកទៅហាលថ្ងៃរយៈពេល១-២ម៉ោង ក្រោយមកទៀតយកទៅត្រាំទឹកក្តៅអ៊ុនៗរយៈពេល១៥-២០នាទី ទើបត្រាំទឹកត្រជាក់ធម្មតា១យប់ បន្ទាប់មកយកទៅផ្អាប់២យប់ នៅពេលគ្រាប់ត្រប់ដុះពន្លកសៗដំបូងអាចយកទៅសាប ឬដាក់ក្នុងកន្ទោងបាន។ របៀបសាបគ្រាប់លើថ្នាលធម្មតា ដំបូងត្រូវរកទីតាំងថ្នាលសាបគឺ ស្រឡះដីទួលស្រស់ទឹក មានជីជាតិល្អ បន្ទាប់មកត្រូវកាប់ហាលដីអោយស្ងួត ទើបលើករងឲ្យបានត្រឹមត្រូវ ដីលើរងគឺឲ្យម៉ត់ល្អកៀរឲ្យស្មើ ទើបយកជីប្រភេទស៊ុបពែផូស្វាតមកបាចពីលើចំនួន១៥០ក្រាម សំរាប់ផ្ទៃថ្នាល១០ម២ ឬជី១៥-១៥-១៥ ចំនួន២០០ក្រាម បន្ទាប់មកពាស់លប់ជីទាំងនោះឲ្យកប់ជ្រៅទៅក្នុងដី។ ការសាបគ្រាប់ពូជត្រូវធ្វើឡើងជាបន្ទាន់ ដោយសាបឲ្យរង្វើលល្មម ក្រោយសាបហើយត្រូវរោយកំទេចចំបើងខ្លីៗពីលើតាមក្រោយ ដើម្បីការពារសំណើមដី បន្ទាប់មកស្រោចទឹកអោយជោគហើយស្រោចសូលុយស្យុងថ្នាំផ្សិត Mancozeb ដើម្បីការពារជម្ងឺរលួយកូនឈ្មោះ Damping off នៅពេលវាដុះថ្មីៗ។ ការស្រោចទឹក ដកស្មៅ និងដាក់ជីបំប៉ន ត្រូវធ្វើឡើងជាប្រចាំដើម្បីឲ្យកូនដំណាំដុះលូតលាស់បានល្អ ក្រោយពីសាបរយៈពេល៣-៤

អាទិត្យ អាចដកយកទៅដាំបាន ។



កូនត្រប់



ខ-ការដាំដុះ: បន្ទាប់ពីលើករងរួច ត្រូវកាប់រណ្តៅតាមបណ្តោយរង ឬថ្នាល ១ថ្នាលដាំ១ជួរគឺចន្លោះជួរ១-១,២ម ចន្លោះគុម្ព៧០-៨០ស.ម ១គុម្ពដាំ១ដើម។ ជំរៅរណ្តៅ ដែលត្រូវកាប់គឺ៨-១០ស.ម ក្នុងករណីកូនត្រប់សាបលើថ្នាលផ្ទាល់ គេត្រូវស្រោចទឹកកូនត្រប់ឲ្យជោគរយៈពេល ២០-៣០នាទី មុននិងដក ដើម្បីបន្ថយការដាច់ឫស។ កូនត្រប់ត្រូវដកពេលព្រឹក បន្ទាប់មកយកវាទៅដាក់ក្នុងឧបករណ៍ដូចជា កញ្ជើរ ល្អី កញ្ជេរ។ល។ ហើយស្រោចទឹកអោយជោគរក្សាទុកនៅក្រោមម្លប់ធ្វើឲ្យកូនត្រប់ មានសភាពរឹងមាំធន់កំដៅថ្ងៃ ក្រោយមកទើបយកទៅដាំនៅពេលថ្ងៃរសៀលចាប់ពីម៉ោង២រហូតដល់ពេលល្ងាចត្រជាក់ ក្រោយពីដាំភ្លាមត្រូវស្រោចទឹកឲ្យជោគតាមរណ្តៅនិមួយៗ។



ទិដ្ឋភាពដំណាំត្រប់





៣.៥-ការស្រោចស្រព: ទឹកជាកត្តាសំខាន់សំរាប់បំលែងសារធាតុចិញ្ចឹមគឺធ្វើឲ្យជីជាតិទាំងឡាយនៅក្នុងដីរលាយ ហើយអាចអោយដំណាំស្រូបយកបានទៅចិញ្ចឹមសរីរាង្គ។ គ្រប់ជាប្រភេទដំណាំមួយដែលត្រូវការទឹកជាប្រចាំ ដើម្បីរក្សាសំណើមដីដូចនេះចាប់ពីពេលដាំភ្លាមត្រូវតែស្រោចទឹកជាបន្ទាន់ ហើយបន្តស្រោចទឹកជាធម្មតាមួយថ្ងៃ១-២លើក ប៉ុន្តែនៅពេលគ្រប់ចាប់ផ្តើមចេញផ្កា រហូតដល់ពេលប្រមូលផលវាត្រូវការទឹកច្រើនជាងពេលដាំ។ ក្នុងដំណាក់កាលនេះ គេអាចបញ្ចូលទឹកដោយម៉ាស៊ីនទៅតាមចន្លោះរងក៏បាន ហើយបាញ់អោយជោគ ធ្វើយ៉ាងណាឲ្យដីមានសំណើមកាន់តែខ្លាំង ជាពិសេសនៅរដូវប្រាំង ។

៣.៦-ការកំចាត់ស្មៅ: ការកំចាត់ស្មៅ គឺគេចាប់ផ្តើមអនុវត្តតាំងពីភ្ជួរដីមក ដោយរាស់ប្រមូលដុតចោលទើបភ្ជួរដី។ ការដាំដុះលក្ខណៈទីផ្សារធំៗ មុនរាស់យកស្មៅចេញ គេប្រើថ្នាំសំលាប់ស្មៅឈ្មោះ Glyphosate ឬGlycine 50ECកម្រិតប្រើ ២,៥លីត្រ លើផ្ទៃដី១ហិកតា ។ វិធីប្រើគឺកំរិត៦០-៧០សេសេ លាយទឹក២០លីត្រ បាញ់លើផ្ទៃដី២០០ម$^{២}$ ក្រោយពីបាញ់រយៈពេល៧ថ្ងៃ ទើបចាប់ផ្តើមរាស់ប្រមូលយកស្មៅចេញហើយភ្ជួរហាលដី។ វិធីសាស្ត្រធ្វើដោយចបគឺ ក្រោយដាំ២អាទិត្យគេត្រូវជ្រុំជ្រួយដីឲ្យផុសល្អ ហាលដី២ថ្ងៃ ទើបពូនរងឡើងវិញដើម្បីឲ្យស្មៅចង្រៃងាប់។ លើកទី២គេអាចជំរះយកស្មៅចេញ តែមិនជ្រុំជ្រួយដីឡើយ។

៣.៧-ការដាក់ជី: ដំណាំត្រប់ត្រូវការប្រើជីមានច្រើនតំណាក់កាលមុនពេលដាំ (ដាក់ទ្រាប់បាត ) ប្រើជី១៥-១៥-១៥ ចំនួន២០០គ.ក្រ ក្នុង១ហិកតា។ ក្រោយដាំ ៧-១០ថ្ងៃ ប្រើជីអ៊ុយរ៉េ ចំនួន៣០-៤០ គ.ក្រ ក្នុង១ហិកតា ដោយលាយទឹកស្រោច ឬ ដាក់ក្បែរគុម្ពហើយស្រោចទឹកក៏បាន។ រយៈពេល៣អាទិត្យក្រោយដាំ គេដាក់បំប៉នជី១៥-១៥-១៥ ចំនួន២០០គ.ក្រ ក្នុង១ហិកតា ដោយដាក់តាមចន្លោះគុម្ព ហើយលប់ដីឲ្យជិតស្រោចទឹកឲ្យជោគ។ លើកចុងក្រោយដាក់ជីអ៊ុយរ៉េចំនួន៥០-៦០គ.ក្រលាយជាមួយជីផូស្វាតចំនួន១០០គ.ក្រក្នុង១ហិកតា នៅពេលត្រប់ចាប់ផ្ដើមប្រមូលផលលើកទី១ មានរយៈពេល៦៥-៧០ថ្ងៃក្រោយដាំ។ ហើយបន្តមកទៀតគេអាចយកជីធម្មជាតិ ដែលត្រាំដូចជា លាមកគោមាន់ ។ល។ ត្រាំរយៈពេលយូរថ្ងៃ យកទៅលាយទឹកស្រោច៧-១០ថ្ងៃម្ដងជួយឲ្យត្រប់ចេញផ្កាបានច្រើន ។

## ៤-ជម្ងឺ និង សត្វល្អិត

### ៤.១-ជម្ងឺសំខាន់ៗ

ក-ក្រុមជម្ងឺផ្សិត: ត្រប់ជាប្រភេទដំណាំមួយ ដែលទទួលរងការបំផ្លាញពីជម្ងឺផ្សិតដូចជា ដើម ស្លឹក ឫស និងផ្លែ

-ជម្ងឺរលួយកូនត្រប់ឈ្មោះ Damping off តាមធម្មតាជម្ងឺផ្សិតតែងតែកើតឡើងដោយលក្ខខណ្ឌអាកាសធាតុ តំបន់ដែលរីកសាយភាយនូវ

ស្ព័រ ព្រមទាំងបណ្ដាលមកពីកត្តាសំណើមនៃដី ។ ជម្ងឺរលួយកូនគ្រាប់នេះ គឺបំផ្លាញកូនគ្រាប់ទើបនឹងដុះ រហូតដល់កូនគ្រាប់មានសន្លឹកពិតលក្ខណៈពិសេសរបស់វាបណ្ដាលមកពីដី ដែលមានមេរោគរស់នៅអាកាធាតុ និងមជ្ឈដ្ឋានសមស្របសម្រាប់ការដុះលូតលាស់ និងសាយភាយនៃជម្ងឺដែលបង្កឡើងដោយពពួកផ្សិតនេះ។

-ជម្ងឺអុចស្លឹកពណ៌ត្នោត Leaf Spots លក្ខណៈជម្ងឺគឺធ្វើឲ្យស្លឹកខ្លោចស្ងួត ដែលមានអង្កត់ផ្ចិតពី៤-៨ម.ម ជួនកាលចំណុចទាំងនេះរីករាលដាលពេញផ្ទៃស្លឹក ធ្វើឲ្យស្លឹកស្ងួតជ្រុះ។

-ជម្ងឺស្ងួតដើមរលួយឫស Verticillium Wilt, Fusarium solani ជម្ងឺនេះច្រើនកើតតែនៅលើដើម និងឫសជាពិសេសពេលគ្រាប់ចាប់ផ្ដើមចេញផ្កា ផ្លែ ធ្វើឲ្យឫសរបស់ដំណាំ រលួយសំបកហើយស្ងួតដើមចាប់ផ្ដើមស្ងួតបណ្ដាលក្នុងហើយមានពណ៌ត្នោត ជ្រុះស្លឹកជាបណ្ដើរៗ ធ្វើឲ្យគ្រាប់ងាប់ទាំងស្រុង។ ក្នុងករណីជួបជម្ងឺនេះច្រើន គឺបន្ថយការដាក់ជី N និងជី K បង្កើនជី Pវិញ មេរោគប្រភេទជម្ងឺនេះរស់នៅក្នុងដីបាន៥ឆ្នាំ ដូចនេះផ្អាកការដាំគ្រាប់លើតំបន់ដែលធ្លាប់រងការបំផ្លាញខ្លាំង។

វិធានការការពារៈ ត្រូវបាចកំបោរសចំនួន២៥០-៣៥០គ.ក្រ ក្នុង១ហិកតា ហើយភ្ជួរលប់រយៈពេល២អាទិត្យទើបរៀបចំដីដាំដោយបាញ់ថ្នាំជម្ងឺមួយអាទិត្យម្ដងៗ ចាប់តាំងពីសាបរហូតដល់គ្រាប់ចេញផ្កានិងផ្លែ។

ខ-ក្រុមជម្ងឺវីរុសៈ គ្រប់ជាប្រភេទដំណាំមួយដែលមានកំរិតធន់ទ្រាំទៅនិងជម្ងឺវីរុសដូចជា Cucumber MosaicVirus, Tobaco Mosaic Virus, Yellow Mosaic Virus ។ វាអាចកើតឡើងដោយកម្រ គឺដោយសារការចម្លងពីភ្នាក់ងារផ្សេងៗដូចជាមមាចជញ្ជក់ស្លឹក ចៃជញ្ជក់ស្លឹក ដើម និងរុយស ។ វិធានការការពារ និងកំចាត់គឺ ដាំពូជធន់ និងកំចាត់សត្វល្អិតដែលជាភ្នាក់ងារចម្លងមេរោគ ។

## ៤.២-សត្វល្អិត

-ដង្កូវស៊ីរូងដើម និងផ្លែ (Eggplant Shoot borer) លក្ខណៈនៃការបំផ្លាញ មេអំបៅតែងតែពងដាក់ស្លឹកផ្នែកខាងក្រោមជារាយៗ ឬជាក្រុមខ្លះទៀតពងដាក់លើផ្កា និងដើមក្រោយមកពងវាញាស់ ហើយចោះចូលទៅក្នុងដើមផ្នែកខ្ចីនៃត្រួយ ឬក្តិបខ្ចីៗ ធ្វើឲ្យត្រួយនៃដំណាំគ្រប់ស្រពោនផ្លែគ្រប់ស្អុយ មិនអាចលូតលាស់បាន ។

-ដង្កូវហ្វូង (Beet army worm) លក្ខខណ្ឌនៃការបំផ្លាញគឺគ្រប់រដូវមេអំបៅពងដាក់លើស្លឹកក្បែរទងផ្លែវាពងជាក្រុមៗ នៅលើពងមានស្បែពណ៌ទឹកក្រូចគ្របពីលើ។ ក្រោយពីញាស់វាចាប់ផ្តើមស៊ីស្លឹកដែលវាទើបនឹងញាស់ក្រោយមកស្លឹកឯទៀតៗ និងទៅផ្លែ ការបំផ្លាញគឺស្លឹក និងផ្លែវាអាចបន្តពូជគ្រប់រដូវ ក្នុងលក្ខខណ្ឌអាកាសធាតុក្តៅសើម ។

-ដង្កូវមូរស្លឹក (Eggplant leaf roller) មេអំបៅរបស់ច្រើនតែពង

ដាក់លើស្លឹកត្រួយខ្ចីៗ ក្រោយពីញាស់វាស៊ីត្រួយហើយរមូរក្តោបរុំការពារខ្លួនវាមិនអោយត្រូវពន្លឺថ្ងៃ និង ការពារសត្រូវធម្មជាតិរបស់វា ។

-អណ្តើកមាស១២ចំណុច (Eggplant beetles) អណ្តើកមាសប្រភេទនេះមានពណ៌ក្រហមស្លាទុំមានចំណុចតូចៗ មូលៗពីលើស្លាបចំនួន៦លើស្លាបម្ខាងៗវាពងដាក់លើស្លឹកត្រប់ផ្នែកខាងក្រោមក្រោយពីញាស់ជាកូនដង្កូវតូចៗវែង វាស៊ីបកយកជាលិកាពណ៌បៃតង ក្រោយមកវិវត្តទៅជាដង្កូវដុះបន្លា ហៅកន្ទិចអាលបន្ទាប់មកទៀតនៅវគ្គចុងក្រោយក្លាយទៅជាអណ្តើកមាសពេញវ័យ ។

ដើម្បីការពារទៅនឹងកត្តាចង្រៃបែបនេះ គេត្រូវអនុវត្តតាមវិធីសាស្ត្រច្រើនយ៉ាងដូចជា: ជ្រើសរើសពូជធន់ទ្រាំល្អ រៀបចំដីអោយបានត្រឹមត្រូវ ផ្លាស់ប្តូរមុខដំណាំជ្រើសរើសរដូវដាំដុះ ដាំឲ្យមានចន្លោះជួរនិងចន្លោះគុម្ពឲ្យបានត្រឹមត្រូវ កាត់រំលួសស្លឹកចោលខ្លះ សំអាតស្មៅនៅក្នុងចំការ ព្រមទាំងវិធានការគីមីរួមផ្សំ ពេលសត្វល្អិតទើបនឹងកកើត។

## ៥-ការប្រមូលផល

ត្រប់អាចប្រមូលផលបានក្រោយពីដាំរយ:ពេលខុសៗគ្នា ទៅតាមប្រភេទរបស់ត្រប់ និងប្រភេទរបស់ពូជ។ ប្រភេទត្រប់ផ្លែខ្ចីដូចជា: ត្រប់ពងមាន់ ត្រប់ក្រាំងរមាស និងត្រប់សណ្តាយផ្លែខ្ចី គឺចន្លោះពី៧០-៧៥ថ្ងៃ ហើយការប្រមូលផលអាចច្រើនលើកអាស្រ័យទៅលើការ

ថែទាំជាពិសេសការកាត់ស្លឹកចាស់ចោល ដាក់ជីបន្ថែម និងស្រោចទឹក។

ចំពោះទិន្នផលជាមធ្យមគ្រប់ក្រាំងរមាស គឺ១១-១៣តោនក្នុង១ហិកតា គ្រប់ពង មាន់ ចន្លោះពី៨-១០តោនក្នុង១ហិកតា រីឯគ្រប់សណ្ដាយផ្លែខ្លី ចន្លោះពី ៧-៩ តោន ក្នុង១ហិកតា ។













# ដំណាំប៉េងប៉ោះ




## ១-លក្ខណៈទូទៅ

ប៉េងប៉ោះស្ថិតនៅក្នុងគ្រួសារ (Solanum L ឈ្មោះវិទ្យាសាស្ត្រ Lycopersicon Esculentum) វាមាននៅអាមេរិចខាងត្បូង ហើយវារីករាលដាលលើពិភពលោកនៅសតវត្សទី១៧។ ដំបូងឡើយប៉េងប៉ោះជារុក្ខជាតិព្រៃ ហើយបន្ទាប់មកគេយកវាទៅដាំលំអនៅក្នុងសួនច្បារនៅទ្វីបអាហ្វ្រិក។ ប៉ុន្តែដោយសារការស្រាវជ្រាវ និង ការបង្កាត់ពូជនៅមជ្ឈមណ្ឌលដំណាំបន្លែនៃទ្វីបអាហ្វ្រិក និង អាមេរិកធ្វើឱ្យលេចចេញនូវប្រភេទពូជយ៉ាងច្រើនខុសៗគ្នា ទៅតាមការចង់បាននៃក្រុមអ្នកវិទ្យាសាស្ត្រ។ ផ្អែកលើការលូតលាស់ និងលក្ខណៈរូប (Genotypes) គេបែងចែកប៉េងប៉ោះជា៣ប្រភេទ:

-ប្រភេទលូតលាស់មិនកំណត់ គឺលូតលាស់មិនបញ្ចប់ទេ ( មានរយៈពេលយូរ ) មានដើមខ្ពស់មែកច្រើន ភាគច្រើនផ្លែមានរាងមូលទ្រវែង ។

-ប្រភេទលូតលាស់ពាក់កណ្ដាលកំណត់ គឺមែកខ្លះបញ្ចប់ការលូត

លាស់ដោយចង្កោមផ្កា តែមែកខ្លះមិនបញ្ចប់ទេនៅតែមានផ្លែផ្កា លើដើមតែមួយ។

-ប្រភេទលូតលាស់កំណត់ គឺបញ្ចប់ការលូតលាស់ដោយចង្កោមផ្កា ដែលមានអាយុកាលខ្លីជាងគេ ។

តារាងអាហារូបត្ថម្ភក្នុងទំងន់១០០ក្រាមបរិភោគបាន

| ទម្ងន់ g | ថាមពល | ទឹក | ប្រូតេអ៊ីន g | ខ្លាញ់ g | កាប៊ូនអ៊ីត្រាត g | Ca mg | Fe mg | P mg | វីតាមីន$B_1$ mg |
|---|---|---|---|---|---|---|---|---|---|
| ១០០ | ២០កាឡូរី | ៩៤ | ១.០ | ០.២ | ៣.៦ | ១០ | ០.៦ | ១៦ | ០.១ |

## ២-បច្ចេកទេសដាំដុះ

### ២.១-ការជ្រើសរើសរដូវ

សីតុណ្ហភាពសមស្របតាមពេលនីមួយៗគឺមានដូចខាងក្រោម:

-ដំណាក់ការលូតលាស់ និងចេញផ្លែចន្លោះពី២១-២៤ អង្សាសេ

-ដំណាក់កាលទុំនៃផ្លែគឺចន្លោះ២៥-២៧ អង្សាសេ

-សីតុណ្ហភាព១២អង្សាសេមិនអាចដុះពន្លក បើកើនលើសពី៣៨ អង្សាសេ ក៏មិនអាចដុះលូតលាស់នៅប្រទេសកម្ពុជាយើង រដូវសមស្របសម្រាប់ការដាំប៉េងប៉ោះគឺរដូវលំហើយចាប់ពីខែ តុលា ដល់ ខែ កុម្ភៈ (ចំពោះពូជប្រកាន់រដូវ) តែតាមការស្រាវជ្រាវអស់រយៈពេល៩ឆ្នាំកន្លងមក(១៩៩៣-២០០១) យើងរកឃើញពូជចំនួន៣ប្រភេទមិនប្រកាន់រដូវ ដែលអាចដាំបាននៅគ្រប់រដូវ។

### ២.២-ការជ្រើសរើសពូជ

ការជ្រើសរើសពូជមានគោលបំណង ក្នុងការណែនាំអ្នកដាំដុះទាំងឡាយឱ្យទទួលបានជោគជ័យក្នុងការដាំដុះ។ ព្រោះបច្ចុប្បន្ននេះប៉េងប៉ោះត្រូវបាននាំចូលតាមរយៈក្រុមហ៊ុននានាក្នុងតំបន់អាស៊ី។ ប៉ុន្តែពូជទាំងនោះសុទ្ធសឹងជាពូជកូនកាត់(Hybrid F1) មិនអាចទុកពូជបានឡើយ ពីព្រោះយកទៅដាំបន្តទៀតវាមិនរក្សាភាពដើមរបស់វាបាន។ របៀបជ្រើសរើសពូជមានៈ

-ពូជមានប្រភពត្រឹមត្រូវ មាន ថ្ងៃ ខែ ឆ្នាំផលិត និង ផុតកំណត់ជាពូជកូនកាត់ រឺ ពូជធម្មតា ។

-ពូជមានអាយុកាលលូតលាស់ខ្លី សមស្របក្នុងតំបន់ដាំដុះ ទិន្នផលខ្ពស់ សមស្របនិងទីផ្សារបច្ចុប្បន្ន ។

-ពូជដែលធន់ទ្រាំទៅនឹងជម្ងឺ ដំណុះគ្រាប់មានភាគរយខ្ពស់ ជាទូទៅគ្រាប់ពូជប៉េងប៉ោះ១០០០គ្រាប់ មានទម្ងន់ប្រហែល២.៥-៣.៥ក្រាម។ ក្នុងមួយហិកតាត្រូវប្រើគ្រាប់ពូជចំនួន ២៥០-៣០០ក្រាម ។

### ២.៣-ការរៀបចំដី

មុននឹងភ្ជួររាស់ដីសំរាប់ដំណាំប៉េងប៉ោះ គេត្រូវរាស់ប្រមូលយកស្មៅចេញ ហើយភ្ជួរដីហាលថ្ងៃឱ្យបានយូរថ្ងៃទើបរាស់បំបែកដីឲ្យហ្មត់ ហើយកៀរឱ្យស្មើ។ ការភ្ជួរនិងរាស់ឱ្យបានច្រើនធ្វើឱ្យដីធូរមានខ្យល់

ចេញចូលគ្រប់គ្រាន់និងសំលាស់ពួកសត្វល្អិតស៊ីដំណាំផ្សេងៗ។ បន្ទាប់មកឆ្វតជារងឱ្យបានសមស្របនៅរដូវប្រាំង ហើយនៅរដូវវស្សាលើករងកំពស់ពី២៥-៣០ស.ម ទទឹងរង១.២ ម ការពារដក់ទឹកពេលភ្លៀង ព្រោះដំណាំប៉េងប៉ោះមិនត្រូវការទឹកដក់យូរពេកទេ ។

### ២.៤-ការបណ្តុះកូន

វិធីសាស្ត្របណ្តុះកូន ដំបូងត្រូវយកគ្រាប់ប៉េងប៉ោះទៅហាលថ្ងៃ១-២ម៉ោង បន្ទាប់មកយកគ្រាប់ទៅត្រាំទឹកក្តៅឧណ្ហៗ ប្រហែល៣០-៤៥អង្សាសេ រួចលាងទឹកឱ្យស្អាត២-៣លើក ផ្អាប់និងក្រណាត់សើមមួយយប់ ហើយយកទៅបណ្តុះក្នុងឯកន្ទោង ឬ សាបលើថ្នាល ដែលរៀបចំជាស្រេច។ នៅក្នុងកន្ទោងបណ្តុះត្រូវដាក់ដី១ភាគ, កំទេចស្រកីដូង១ភាគ និង ផេះអង្កាមចំនួន១ភាគ លាយបញ្ចូលគ្នា ហើយដាក់នៅក្នុងកន្ទោង។ បន្ទាប់មកយកគ្រាប់ដាក់ដាំក្នុងជំរៅ ប្រហែល១-២ ម.ម គេដាក់២-៣គ្រាប់ក្នុងមួយកន្ទោង រួចយកចំបើងស្ងួតគ្របពីលើ ហើយស្រោចទឹកព្រឹក ល្ងាច២-៣ដង/មួយថ្ងៃ។ ការសាបកូនលើថ្នាលជាធម្មតាបន្ទាប់ពីផ្អាប់១-២យប់មក គេត្រូវយកគ្រាប់ពូជទាំងនោះ ទៅសាបលើថ្នាលដែលរៀបចំរួច។ ក្រោយពីសាបប្រហែល៩-១០ថ្ងៃ ទើបអាចដករំលួសកូនយកទៅស្ទូងកន្លែងផ្សេង ដើម្បីឱ្យកូនប៉េងប៉ោះរឹងមាំ។ ក្រោយពីដករំលួស ១៣-១៥ ថ្ងៃគេអាចដកកូនយកទៅដាំបាន ។

### ២.៥-ការដាំដុះ

ការដាំត្រូវមានចន្លោះគុម្ព៧០ស.ម, ចន្លោះជួរ១ម, មួយគុម្ព១ដើម។ ក្រោយដាំហើយ ត្រូវស្រោចទឹកដើម្បីការពារកុំឱ្យប៉េងប៉ោះស្វិត។ ចំពោះកូនសាបលើថ្នាលត្រូវស្រោចទឹកថ្នាលឱ្យជោគមុនពេលដកយកទៅដាំ គេត្រូវដាំវានៅពេលរសៀល រឺ ពេលមេឃត្រជាក់ ។

## ៣-ការថែទាំ

ការថែទាំដំណាំមានដូចជា កំចាត់ស្មៅ, ជ្រួយដី, ស្រោចទឹក, ដោតចំណារ,ចងដើម,កាត់មែកនិងដាក់ជី។

**៣.១-ការជ្រួយដី** ពូនគល់និងកំចាត់ស្មៅការជ្រួយដីពូនគល់គឺប្រយោជន៍ធ្វើឲ្យដីធូរមានខ្យល់ចេញចូលគ្រប់គ្រាន់ រក្សាសំណើមបានល្អដើម្បី ឱ្យសារធាតុចិញ្ចឹមបំបែកធាតុបានឆាប់ ធ្វើឱ្យដំណាំអាចលូតលាស់បានល្អ និង ម៉្យាងទៀតដើម្បីការពារស្មៅដុះ។ របៀបជ្រួយដី និងពូនគល់ គឺជ្រួយបំបែកដីឱ្យផុសហើយកៀរពីបាតរងឱ្យស្មើមកលប់គល់ដំណាំ ដើម្បីងាយស្រួលក្នុងការស្រោចស្រព គឺធ្វើឡើងក្រោយដាំរយៈពេល១០-១២ថ្ងៃ។ ក្រោយពេលដាំបានរយៈពេល៣៥-៤០ថ្ងៃ ត្រូវដកស្មៅចេញហាមជ្រួយដី។

**៣.២-ការស្រោចស្រព** ប៉េងប៉ោះមិនត្រូវការទឹកជោគជាំដូចស្ពៃឡើយ វាត្រូវការសំណើមដីជាប្រចាំ។ ការស្រោចទឹកត្រូវបែងចែកជាបី

ដំណាក់កាលគឺ:

➤ដំណាក់កាលទី១: ចាប់ពីដាំដុះរហូតដល់ពេលចេញផ្កាដំបូង វាត្រូវការទឹកជាមធ្យម សំណើមដីប្រមាណពី៦៥-៧០%។

➤ដំណាក់កាលទី២: ចាប់ពីចេញផ្ការហូតដល់ផ្លែចាស់ វាត្រូវការទឹកពេញលេញជារៀងរាល់ថ្ងៃ គឺស្រោចទឹកព្រឹកល្ងាច កំរិតទឹកច្រើន ឬមធ្យមវាអាស្រ័យលើប្រភេទដី។ ប្រសិនបើដីលាយខ្សាច់តំរូវការទឹកច្រើនជាងដីល្បប់ (Loam soil) គឺសំណើមដីប្រមាណ ៧៥-៨៥% ជាប្រចាំ។

➤ដំណាក់កាលទី៣:ចាប់ពីផ្លែធំចំណាស់រហូតដល់ទុំ វាត្រូវការទឹកមធ្យម ដូចដំណាក់កាលទី១ ដែលកើនលើសបន្តិច គឺវាអាស្រ័យទៅតាមប្រភេទពូជ ប្រសិនបើ ពូជលូតលាស់មិនកំណត់ វាតែងតែចេញផ្លែបន្តជាច្រើនលើក។ គេអាចស្រោចដោយប៉ោត ដោយប្រើម៉ាស៊ីនបាញ់ ឬ បូមបញ្ចូលតាមបន្លោះរង១-២ដងក្នុង ១សប្ដាហ៍អាស្រ័យទៅតាមប្រភេទដីនិងសីតុណ្ហភាព ។



ការស្រោចស្រព

៣.៣-ការដោតចំណារ និងកាត់មែក ជាទម្លាប់របស់កសិករយើង

ពីមុនៗមកការដាំប៉េងប៉ោះមិនទំលាប់ដោតចំណារឡើយ គឺទុកឱ្យវាដុះលូតលាស់តាមធម្មតាលើដី។ លក្ខណៈទាំងនេះធ្វើឱ្យផ្លែស្អុយបាត់បង់ទិន្នផលជាច្រើន។ ប៉ុន្តែក្រោយមកការពិសោធន៍ស្រាវជ្រាវនៅមជ្ឈមណ្ឌលដំណាំបន្លែអាស៊ី (AVRDC) និងនៅសហរដ្ឋអាមេរិកគឺការពិសោធន៍ដាំដុះដោយដោតចំណារ ឬដាក់ស្នួរឱ្យដើមឈរ ត្រង់ផុតពីដីធ្វើឱ្យទិន្នផលកើនឡើងយ៉ាងខ្លាំង។ នៅតំបន់ជាច្រើនកសិករតែងតែដាំដោយដោតចំណារ ជាពិសេសនៅរដូវវស្សាចំណារត្រូវដោតឱ្យឈរត្រង់ហើយចងចុងរបស់វាជាប់គ្នា ដើម្បីការពារការដួលរលំ។ រួចហើយត្រូវចងដើម មែក ឱ្យជាប់ និងចំណារនោះការពារកុំឱ្យផ្លែដល់ដី។ គេដោតចំណារនៅពេលប៉េងប៉ោះចាប់ផ្ដើមចេញផ្កា។ ម៉្យាងទៀតគេត្រូវការរំលូសមែកខាងក្រោមមួយចំនួនចេញ ដើម្បីឱ្យស្រឡះអាចការពារបាននូវភាពឆ្លងជម្ងឺ និងជំរកសត្វល្អិត ។



ទិដ្ឋភាពដំណាំប៉េងប៉ោះ





**៣.៤-ការដាក់ជី** ដំណាំប្រភេទនេះត្រូវការសារធាតុចិញ្ចឹមច្រើន មុខជាពិសេសគឺ:អាសូត ផូស្វរ័ កាល់ស្យូម និងសូដ្យូម។ ប៉ុន្តែសារធាតុ អាសូត ផូស្វរ័ និង ប៉ូតាស្យូម ជាកត្តាសំខាន់ជាងគេ ដែលវាត្រូវការ ហើយអាសូត និង ប៉ូតាស្យូមត្រូវការច្រើនជាងផូស្វរ័។ ដូច្នេះការដាក់ជី ត្រូវបានបែកចែកជាបួនដំណាក់កាលដូចខាងក្រោម:

➤ដំណាក់កាលទី១: មុនពេលដាំត្រូវដាក់ជីកំប៉ុស្ត ឬលាមកសត្វ ចំនួន១០-១៥តោន/ហិកតា ហើយរាស់ដីលប់ទើបដាំជាក្រោយ។

➤ដំណាក់កាលទី២: ប្រើអ៊ុយរ៉េសុទ្ធចំនួន ៨៧ គក្រ/ហិកតា ដោយលាយជាមួយទឹកស្រោចក្រោយដាំរយះពេល៥-៧ថ្ងៃ។

➤ដំណាក់កាលទី៣: ដាក់តាមចន្លោះគុម្ពក្រោយពេលជ្រុំដី គឺ ក្រោយដាំ៣សប្តាហ៍មានប្រភេទជី ១៥-១៥-១៥ ចំនួន២០០គក្រ/ហិកតា លាយជាមួយជីប៉ូតាស្យូម(00.00. 60)ចំនួន១០០គក្រ/ហិកតា។

➤ដំណាក់កាលទី៤: ដាក់ក្រោយដាំរយ:ពេល៧សប្តាហ៍ ដាក់ជី អ៊ុយរ៉េចំនួន៨៧គក្រ/ហិកតា លាយទឹកស្រោចចំគល់ ហើយស្រោចទឹក លាងតាមក្រោយ ។



## ៤-អំពីជម្ងឺ និងសត្វល្អិត

ដំណាំប៉េងប៉ោះជួបការបំផ្លាញដោយជម្ងឺច្រើនយ៉ាង ទោះបីជារដូវប្រាំងក៏ដូចជា រដូវវស្សាដែរ ។

### ៤.១-អំពីជម្ងឺសំខាន់ៗ

ស្ទើរគ្រប់រដូវប៉េងប៉ោះតែងរងការបំផ្លិចបំផ្លាញដោយជម្ងឺសំខាន់ៗ ៣គឺ វីរុស, បាក់តេរី និងផ្សិត។ ក្រៅពីនេះទៀតមានជម្ងឺកង្វះសារធាតុចិញ្ចឹម ក៏តែងតែកើតឡើងដែរដូចជាកង្វះជាតិកំបោរនិងកាល់ស្យូមជាដើម។

ក.ជម្ងឺវីរុស: នៅប្រទេសកម្ពុជាយើងជម្ងឺវីរុស ដែលតែងតែរាតត្បាតលើដំណាំប៉េងប៉ោះមាន៤ប្រភេទដូចជា:

-ជម្ងឺស្លឹកបែតងចាស់: Tomato Masaic Virus (ToMV)គឺស្លឹកវាពណ៌បៃតងចាស់ហើយរួញបន្តិចៗ លេចចេញពេលប៉េងប៉ោះចេញផ្កា ១០០% និងចាប់ផ្តើមផ្លែ។ ការចម្លងបណ្តាលមកពីមនុស្ស ឬ សត្វទៅប៉ះពាល់លើដើមផ្សេងទៀត ឬ តាមរយៈគ្រាប់ពូជកាលពីរដូវមុន។

-ជម្ងឺរួញស្លឹកពណ៌ដូចត្រួយត្រសក់បៃតងខ្ចី Cucumber Mosaic Virus (CMV) វាតែងតែកើតឡើងក្នុងតំណាក់កាលចេញផ្លែគឺធ្វើឱ្យស្លឹកកំពូលប្រែពីពណ៌បៃតងព្រឿងៗ ឬពណ៌លឿង ហើយរាងកោងខ្ទូរបន្តិច ជម្ងឺនេះភាគច្រើនចម្លងដោយពពួកចៃ ដែលនៅក្នុងខ្លួនវាផ្ទុកជម្ងឺវីរុស

ហើយចម្លងពីដើមមួយទៅដើមមួយទៀត។

-ជម្ងឺរួញស្លឹកដោយមិនប្រែពណ៌តែមានចំណុចអុចៗលើផ្ទៃស្លឹក: Tomato Wilt Virus (TSWV)ដំបូងលូតលាស់ធម្មតា។ ប៉ុន្តែក្រោយមក លេចចេញជាចំណុចៗនៅលើស្លឹកកំពូលនៃត្រួយ ហើយរាលដាលមក ស្លឹកចាស់ វាបង្កនិងចម្លងជម្ងឺដោយសត្វទ្រីបដែលជាភ្នាក់ចម្លងរោគ។

-ជម្ងឺរួញស្លឹក Tomato Yellow Leaf Curl Virus (TYLCV) តែងតែកើតមាននៅគ្រប់រដូវ វាបង្កឡើងដោយវីរុស ដែលរុយសជាអ្នកចម្លងជម្ងឺ ហើយពុំមានថ្នាំកំចាត់វាឡើយ។ គេត្រូវតែដកដើមដែលកើតជម្ងឺនេះ ចោលបំបាត់ជំរក និង កំចាត់សត្វល្អិតដែលជាភ្នាក់ងារចំលងជម្ងឺ និង បាញ់ថ្នាំផ្សំពីរុក្ខជាតិការពារព្រមទាំងដាំពូជធន់ជ្រើសរើសរដូវសមស្រប សំរាប់ដាំដុះ។

ខ-ជម្ងឺផ្សិត: ជម្ងឺផ្សិតដែលកើតលើដំណាំប៉េងប៉ោះមានច្រើនប្រភេទដូចជា: ផ្សិតនៅគល់, ផ្សិតនៅលើស្លឹក និងផ្សិតនៅឫស។

-ជម្ងឺផ្សិតម្សៅលើស្លឹក:(Powdery Mildew) វាកើតនៅរដូវត្រជាក់ស្ងួត វាធ្វើឱ្យស្លឹកមានម្សៅពណ៌សៗ ក្រោយមកស្លឹកនោះក៏ស្ងួតជ្រុះ វាបង្កដោយពពួកផ្សិតឈ្មោះ Leveillula Taurira។

-ជម្ងឺផ្សងស្លឹក (Leaf Mould) វាកើតផ្សិតខ្មៅៗជាំដុំៗលើស្លឹក ពិសេសគឺស្លឹកក្បែរដី។ វាបង្កឡើងដោយពពួកផ្សិត។

-ជម្ងឺផ្សិតជុំវិញគល់ច្រើនប្រភេទ Stem Rot or Southem Blight វាកើតឡើងមិនរើសរដូវឡើយ ជាពិសេសច្រើនកើតលើពូជដែលមិនធន់ ហើយកើតនៅពេលវាចេញផ្កា ។

-ជម្ងឺរលួយឫស Fusarium Wilt វាបណ្ដាលមកពីសំណើមដីខ្ពស់ពេកលើសសេចក្ដីត្រូវការបណ្ដាលឱ្យឫសរលួយ និងពុក វាច្រើនកើតនៅរដូវវស្សា ហើយធ្វើឱ្យប៉េងប៉ោះស្រពោនជ្រុះស្លឹក។ វាកើតក្នុងដំណាក់កាលលូតលាស់ និង ចេញផ្លែ។

វិធានការការពារ កំចាត់ឱ្យជម្ងឺទាំងនេះគឺត្រូវជ្រើសរើសពូជធន់, ដីឱ្យល្អ, ភ្ជួរហាលដីឲ្យបានយូរថ្ងៃ, ផ្លាស់មុខដំណាំ, បន្ថយការស្រោចទឹក, ដកស្មៅឱ្យបានស្អាតពីចំការ និងប្រើប្រាស់ប្រភេទថ្នាំផ្សិត។

គ.ជម្ងឺបាក់តេរី: ប៉េងប៉ោះជួបការបំផ្លាញដោយជម្ងឺបាក់តេរី២យ៉ាងគឺ: បាក់តេរីស្រពោនដើម និងបាក់តេរីអុចស្លឹក ដើម និងផ្លែ។

-ជម្ងឺបាក់តេរីស្រពោនស្លឹក Bacteris Wilt: ច្រើនកើតក្នុងដំណាក់កាលកំពុងផ្លែគឺធ្វើឲ្យស្រពោនរហូតដល់ងាប់ទាំងស្រុង។ វាបង្កឡើងដោយមេរោគឈ្មោះ Ralstonia Solanacearum ។ ដើម្បីទប់ស្កាត់ជម្ងឺនេះ គេត្រូវជ្រើសរើសពូជធន់ និងដាំផ្លាស់មុខដំណាំ រឺផ្អាកការដាំរយៈពេល៣-៤ឆ្នាំ ព្រោះមេរោគរស់នៅក្នុងដីរយៈពេលពី ៤-៥ ឆ្នាំ។

-ជម្ងឺបាក់តេរីអុចស្លឹក ដើម និងផ្លែ: ភាគច្រើនកើតនៅរដូវវស្សា វាមានឈ្មោះថា Bacteria Spot វាធ្វើឲ្យដើម ស្លឹក ផ្លែ មានចំណុចអុចៗដូចប្រជ្រុយ ហើយធ្វើឱ្យស្លឹកឡើងពណ៌ច្រេះដែក ធ្វើឱ្យប៉េងប៉ោះជ្រុះស្លឹក និងផ្លែទុំមិនក្រហម។ គេកំចាត់វាដោយកំចាត់ស្មៅក្នុងចំការ ដាំឱ្យរង្វើល កាត់ស្លឹក រឺ មែកក្បែរដីចេញ និងយកថ្នាំ ប្រភេទ Copper hydroxide 80%wp កំរិត២៥-៣០ក្រាម លាយជាមួយទឹក១៥-២០លីត្របាញ់រយៈពេល៥-៧ថ្ងៃម្តងនៅពេលចេញជារោគសញ្ញា។

### ៤.២-អំពីសត្វល្អិតស៊ីដំណាំ

សត្វល្អិតសំខាន់ៗ លើដំណាំប៉េងប៉ោះមានច្រើនប្រភេទ ខ្លះបំផ្លាញផ្ទាល់ដូចជាអណ្តើកមាសចំណុច (បំផ្លាញទាំងដង្កូវ និងមេ ) វាជាភ្នាក់ងារបង្កជម្ងឺ ។

-ដង្កូវហ្វូងស៊ីស្លឹក (Army Worm Spodoptera Litura) ជាដង្កូវមានមាឌធំវែង ពណ៌ចំរុះ ខ្មៅត បៃតង ឬបៃតងចាស់។ ពេលវាទើបនឹងញាស់វាស៊ីជាក្រុម តែវាធំដល់ដំណាក់កាលទី៣ (ធំប៉ុនជើងធូប) វារកស៊ីផ្សេងៗគ្នា លុះក្រោយមកវាឆ្លងទៅស៊ីស្លឹក ឬ ដើមផ្សេងទៀត។ វាចូលចិត្តជ្រកនៅក្រោមស្មៅក្រោមស្លឹកដំណាំ និងចូលតាមក្រហែងដីពេលថ្ងៃក្តៅ ហើយពេលត្រជាក់ទើបវាចេញមកស៊ី។

-ដង្កូវចោះផ្លែ: វាតែងតែស៊ីចោះចូលក្នុងផ្លែ ធ្វើឱ្យផ្លែប៉េងប៉ោះ

ស្អុយរលួយ។ ក្រុមចោះផ្លែនេះមានពីរប្រភេទដូចជាក្រុមមានរោមឈ្មោះ Tomato Fruit Worm ដែលមានពណ៌ខៀវ និងមួយប្រភេទទៀតឈ្មោះ Beet Army Worm កកេរស៊ីមែក និង ស្លឹកខ្ចីៗ។

-ក្រុមសត្វដែលជាភ្នាក់ងារបង្ករោគ មានមមាចជញ្ជក់ស្លឹក(Leaf Hopper ) ចៃបៃតង(Geen Peach Aphid) រុយស (White fly ) ទ្រីប (Thrips)។ ឥទ្ធិពលរបស់វាគឺបំផ្លាញ និងបង្កឱ្យកើតជម្ងឺរួញស្លឹក(វីរុស) ។

វិធានការការពារ និងកំចាត់សត្វល្អិតទាំងនេះគឺ: ការជ្រើសរើសរដូវដាំដុះ ជ្រើសរើសពូជធន់ រៀបចំដីឲ្យបានល្អ ដាំឱ្យមានចន្លោះគុម្ពត្រឹមត្រូវ , កាត់មែក រឺ ស្លឹកមួយចំនួនចោល , ដោតចំណារ ចងដើមឱ្យស្រឡះពីដី និង ការប្រើថ្នាំកសិកម្មប្រភេទណាដែលកំចាត់វាបាន។ ប៉ុន្តែយើងត្រូវដឹងពីដំណាក់កាលរបស់សត្វល្អិតទាំងនោះ ពេលវានៅតូចទើបនឹងញាស់ ទើបការបាញ់ថ្នាំគឺមានប្រសិទ្ធិភាព គឺបាញ់នៅពេលមេឃត្រជាក់។

## ៥-ការប្រមូលផល

ការប្រមូលផលប៉េងប៉ោះត្រូវធ្វើឡើងក្រោយពីដាំបានរយៈពេលពី ៦០-៧០ថ្ងៃទៅតាមប្រភេទពូជនិងការដាំដុះ។ ចំពោះពូជដែលមានអាយុកាលខ្លី គឺចន្លោះ៥៥-៦០ថ្ងៃ គេកាត់ផ្លែប៉េងប៉ោះដោយកន្ត្រៃ ប្រសើរជាងបេះយកតែផ្លែ ធ្វើឱ្យការរក្សាទុកមិនបានយូរថ្ងៃផ្លែដែលអាចបេះបានគឺ

អាស្រ័យទៅតាមតម្រូវការទីផ្សារមានទុំ ២៥% ឬ ទុំ ៦៥%(ប្រែពណ៌ពីបៃតងទៅក្រហមព្រឿងៗ)។ ចំពោះពូជធ្ងន់អាយុកាលលូតលាស់វែងពី ៦០-៧០ថ្ងៃ ពូជនេះច្រើនតែផ្លែបន្តគ្នាច្រើនដំណាក់កាល។ ការប្រមូលផលធ្វើឡើងច្រើនដងចំពោះផ្លែទុំអាស្រ័យទៅតាមតម្រូវការ។ តែបើប៉េងប៉ោះសំរាប់កែច្នៃ គឺគេទុកឱ្យវាទុំពី៧៥-៨០% គឺក្រហមស្ទើរតែទាំងអស់លើផ្លែនីមួយៗ ផលិតផលប៉េងប៉ោះនៅប្រទេសកម្ពុជាយើងចែកចេញជា៣ប្រភេទគឺ៖

-ប្រភេទពូជដែលកសិករទុកដោយខ្លួនឯង (ពូជក្នុងស្រុក) ផ្តល់ទិន្នផលទាបចន្លោះពី១២-១៦តោន/ហិកតា

-ពូជទំនើបផលិតដោយស្ថានីយ៍ក្បាលកោះដូចជា: TMK1 , TMK2 , TMK3 ផ្តល់ទិន្នផលមធ្យមចន្លោះ២៤-២៨តោន/ហិកតា

-ពូជនាំចូលពីបរទេស ផ្តល់ទិន្នផលប្រហាក់ប្រហែលនឹងពូជទំនើប។







# ឯកសារយោង


១-សៀវភៅណែនាំអំពីការគ្រប់គ្រងសត្វល្អិត និងជម្ងឺលើដំណាំបន្លែ ភាគ ២, គម្រោងQCAM(JICA) ឆ្នាំ២០១២

២-សៀវភៅណែនាំ អំពីការគ្រប់គ្រងសមាសភាពចង្រៃ, គម្រោង QCAM (JICA) ឆ្នាំ២០១១

៣-ឯកសារជំនួយបច្ចេកទេសដំណាំបន្លែ vvob, ឆ្នាំ២០១១

៤-កម្រងឯកសារបច្ចេកទេសដំណាំបន្លែ, អង្គការអាគ្រីយៃមឆ្នាំ២០១១

៥-បច្ចេកទេសដាំដំណាំបន្លែ, អគ្គនាយកដ្ឋានកសិកម្ម ឆ្នាំ២០១១

៦-បច្ចេកទេសដាំបន្លែសម្រាប់មន្ត្រីផ្សព្វផ្សាយ, នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និង ក្រុមហ៊ុន EAST-WEST SEED INTERNATIONAL

៧-គោលការណ៍ណែនាំសម្រាប់ធ្វើអត្តសញ្ញាណកម្ម និងការគ្រប់គ្រងជម្ងឺលើដំណាំបន្លែ IPM, ២០០៨

៨-គុណភាពផលិតកម្មដំណាំបន្លែ, កម្មវិធីអេគីប ឆ្នាំ២០០៥

៩-សត្វល្អិត និ ងជម្ងឺលើដំណាំអំបូរស្ពៃ, លោក ម៉ុង វ៉ាន់ឌី ស្ថានីយ៍ក្បាលកោះ ឆ្នាំ២០០៤

១០-ដំណាំបន្លែនៅកម្ពុជា, លោក ម៉ុង វ៉ាន់ឌី ស្ថានីយ៍ក្បាលកោះ ឆ្នាំ២០០២

១១-គេហទំព័រ